មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ សាន់ រឿង ភេទប្រុស

## រស់នៅភូមិអភិវឌ្ឍន៍ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ លឹម ជ័យឧត្តុ

## ០១ៈ២៨ៈ៣៣

## ៣៦ទំព័រ

ជ័យឧត្តុៈ ពូខ្ញុំសុំសួរពូចាប់ផ្តើម មុនដំបូងខ្ញុំចង់ជំរាបពូខ្ញុំឈ្មោះ លឹម ជ័យឧត្តុ ហើយមិត្តភក្តិខ្ញុំនេះឈ្មោះប្រុញ ថ្ងៃនេះចង់សុំសួរពូទាក់ទងពីរឿងប្រវត្តិពីមុនៗមក ដើម្បីយកប្រវត្តិរស់ហ្នឹងចងក្រងដាក់ចូលសៀវភៅអប់រំក្មេងជំនាន់ក្រោយ ។ ក្មេងជំនាន់ក្រោយបានដឹងពីប្រវត្តិសាស្ត្ររបស់យើង ហើយបានដឹងពីតំបន់អន្លង់វែងហ្នឹងផង អីចឹងប្រហែលជាពូបានដឹងច្បាស់ ហើយដឹងច្រើន អីចឹងសុំសួរពូ ។ ជាដំបូងខ្ញុំចង់សួរពូពីប្រវត្តិពូពីក្មេងៗមក ។

រឿងៈ អីចឹងកាលនោះខ្ញុំឈ្មោះ ។

ជ័យឧត្តុៈ ឈ្មោះ ។

រឿងៈ ខ្ញុំឈ្មោះ សាន់ រឿង ខ្ញុំចូលកងទ័ពនៅឆ្នាំ១៩៧២ ពេលហ្នឹងខ្ញុំមានអាយុ១៧ឆ្នាំ ឆ្នាំ១៩៧០លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុពីអំណាច ដល់អីចឹងខ្ញុំកាលហ្នឹងខ្ញុំមានអាយុ១៥ឆ្នាំ រហូតដល់៧២ខ្ញុំមានអាយុ១៧ឆ្នាំ ។ កាលហ្នឹងបាតុកម្ម១៨ មិនាខ្ញុំបានចូលរួមដែល កាលនោះខ្ញុំនៅធ្វើស្រែប្រាំងនៅជប់ មេមត់ ដល់ពេលថ្ងៃ១៨ មិនាខ្ញុំធ្វើដំណើរមកផ្ទះគេឲ្យមកធ្វើបាតុកម្ម មកដល់ស្ពានជ្រោយចង្វារ កាលហ្នឹងខ្ញុំនៅអាយុ១៥ទេ អីចឹងខ្ញុំដឹងហើយ ហ្នឹងខ្ញុំនិយាយប្រវត្តិខ្ញុំកាលពីក្មេង ។ ពេលហ្នឹងគឺបានធ្វើបាតុកម្មចូលរួមជាមួយចលនាតស៊ូ កាលហ្នឹងមានសម្តេចឪយើង ប្រធានរណសិរ្សកំលាំងតស៊ូ ស្រាប់តែដល់ស្ពានជ្រោយចង្វារ ខាងទីក្រុងភ្នំពេញគេដាក់មេក្រូស្រែកមកថា ឲ្យបងប្អូនយើងត្រឡប់ទៅកំពង់ចាមវិញ ថាសម្តេចឪយើងមានកាំភ្លើង មានគ្រាប់ អីចឹងយើងចាញ់នយោបាយគេ បាតុកម្មគ្រាន់តែបានត្រឹមប៉ុណ្ណឹងអត់បានឆ្លងទេ បើអីចឹងយើងចាញ់ឃោសនាគេ ស្រាប់តែពួកបាតុកម្មហ្នឹងខ្ញុំបានចូលរួមដែរ ត្រឡប់មកវិញ មកដល់គេហៅថ្នល់កែង បាធាយ ស្រាប់តែគេចាញ់ឃោសនាទាហាន លន់ នល់ទេ អីចឹងកំលាំងបាតុកម្មយើងត្រូវត្រឡប់មកវិញ ដល់លន់ នល់ គេរៀបចំកាំភ្លើងរួចស្រេច ស្រាប់តែយើងទៅដល់គេបាញ់ ។

ជ័យឧត្តុៈ គេបាញ់អត់មានរើស គឺបាញ់យកតែម្តង?

រឿន: បាញ់ ចុះយើងបាតុកម្មគាំទ្រចលនាសម្ដេចសីហនុ មានជ័យឃោសថា “ជយោសម្ដេចឪ អ្នកណាមិនទៅកាប់ចោល” ហ្នឹងពាក្យអីចឹង ។

ជ័យទត្ត: យើងប្រើពាក្យអីចឹងតែម្ដង?

រឿន: បាទ! ពាក្យអីចឹង យើងទៅចូលរួមព្រោះកាលហ្នឹងចលនារបស់សម្ដេច យើងចូលរួមណាស់ ហើយយើងមានជំនឿលើសម្ដេចឪណាស់ អីចឹងប្រជាជនពេលហ្នឹងឯរឿងបដិវត្តន៍មិនទាន់ចូលជ្រៅទេ ។ គេថាសម្ដេចសីហនុលក់ខត្តមកគិឲ្យទៅកុំមុយនីស្តតាមខ្ញុំលឺ ខាងលន់ នល់ អីចឹងមានកំលាំងតស៊ូ១៨ មិនា ចូលទៅដល់គេបាញ់ ស្លាប់និងរបួសច្រើន ដល់អីចឹងគេថារបបកុំមុយនីស្ត ថាសម្ដេចឪយើងរបបកុំមុយនីស្ត លន់ នល់ចោទ ។ ដល់អីចឹងកំលាំងចលនាត្រឡប់មកវិញទៅ ហើយមានសេចក្ដីអំពាវនាវរបស់សម្ដេចសីហនុឆ្នាំ៧២ ។ មានអ្នកដឹកនាំដែរ បើអីចឹងយើងថាត្រឡប់ទៅតំបន់ មកស្រុក មកភូមិវិញ ដើម្បីធ្វើចលនា ពេលនោះឆ្នាំ១៩៧២ ។

ជ័យទត្ត: ពូខ្ញុំសុំកាត់បន្តិច ពេលហ្នឹងទាហានលន់ នល់ បាញ់មកក្រុមបាតុកម្មស្លាប់ប្រហែលប៉ុន្មាននាក់?

រឿន: ស្លាប់ច្រើនអូន មិនស្លាប់តិចទេ ។

ជ័យទត្ត: បាញ់ហ្នឹងម្តុំណាពូ?

រឿន: បាញ់ម្តុំស្ពានជ្រោយចង្វារ ។

ជ័យទត្ត: ម្តុំស្ពានជ្រោយចង្វារពេលដែលពួកប្រជាជនមកតវ៉ាហ្នឹង?

រឿន: បាទ! ដំបូងគេប្រាប់ដែលថាកុំឲ្យចូលៗ យើងចេះតែចូល គេបាញ់ប្រហើរទៅៗ ដល់មែនទែនគេបាញ់ឲ្យត្រូវ យើងឃើញរបួស ឃើញស្លាប់យើងត្រឡប់មកវិញ ។

ជ័យទត្ត: តែពូមានដឹងប្រហែលប៉ុន្មាន?

រឿន: អត់ដឹងចំនួនទេអូន តែការស្លាប់ៗច្រើន ព្រោះយើងមិនចេះក្បួនយុទ្ធសាស្ត្រ ប្រជាពលរដ្ឋទម្លាក់សម្ដេចឪពីអំណាចគឺគាំទ្រចលនារបស់ព្រះពុទ្ធ ។

ជ័យទត្ត: បាតុកម្មថ្ងៃប៉ុន្មាន ខែ?

រឿន: បាតុកម្មថ្ងៃ១៨ មិនា ។

ជ័យទត្ត: ពេលទម្លាក់ភ្លាមមកភ្លាម?

រឿន: អត់ទេ ទម្លាក់ឆ្នាំ១៩៧០ ។

ជ័យទត្ត: ៧០ ១៨ មិនា? ចុះថ្ងៃបាតុកម្ម ថ្ងៃណា?

រឿន: ខ្ញុំអត់ដឹង កត់ត្រាទុកទេ ។

ជ័យទត្តៈ	តែដឹងថាកៀកៗទម្លាក់ហើយភ្លាម?

រឿងៈ	បាទ! ពេលទម្លាក់ហើយមានចលនាបាតុកម្ម ។

ជ័យទត្តៈ	អាច១សប្តាហ៍ ឬពីរសប្តាហ៍?

រឿងៈ	អត់ទេ ប្រហែលជាមិនដល់មួយសប្តាហ៍ទេ ។

ជ័យទត្តៈ	អីចឹងបន្ទាប់ពីទម្លាក់ភ្លាម មកភ្លែត?

រឿងៈ	បាទ! ទម្លាក់ភ្លាមដល់គេធ្វើចលនារយៈ១-២ខែដែរ អីចឹងមានការសម្លាប់ និងរបួសយើងក៏ត្រឡប់មកវិញ ស្រាប់តែមានបដិវត្តន៍កើតឡើង ។ បដិវត្តន៍ហ្នឹងគេនិយាយពីអ្នកក្រឡើងកាន់អំណាច បដិវត្តន៍ស្មើរភាពគ្នា ស្រាប់តែខ្ញុំត្រឡប់មកផ្ទះវិញ ឆ្នាំ១៩៧២ខ្ញុំមានអាយុ១៧ឆ្នាំ ស្រាប់តែលឺសម្តេចអំពាវនាវតាមប៉ុស្តិ៍វិទ្យុ សម្តេចឪយើង កាលនោះមួយភូមិៗមិនសូវមានវិទ្យុទេ មួយភូមិៗមាន២-៣គ្រឿងទេ ដល់អីចឹងយើងលឺសូរចលនារបស់សម្តេចឪ ថាកូនចៅរត់ចូលព្រៃម៉ាគី ដើម្បីវ៉ៃរបបចក្រពត្តិអាមេរិក-លន់ នល់ ដើម្បីរំដោះរបបសង្គមរាស្ត្រនិយមយើងមកវិញ ហើយយើងក៏គាំទ្រ ។

ជ័យទត្តៈ	ពេលហ្នឹងពូសំរេចចិត្តចូលបដិវត្តន៍?

រឿងៈ	ចូលកងទ័ព ចូលនៅក្នុងភូមិហ្នឹងហើយ គេនិយាយពីរឿងបែងចែកវណ្ណៈ យើងមានការឈឺចាប់ក៏យើងបានចូលកងទ័ព ។

ជ័យទត្តៈ	ភូមិណា?

រឿងៈ	ខ្ញុំនៅភូមិពាមលាន់ ស្រុកព្រៃឈរ កំពង់ចាមយើង ។

ជ័យទត្តៈ	ភូមិពាមលាន់ ឃុំ?

រឿងៈ	ឃុំល្វា ។ ដំបូងខ្ញុំចូល២នាក់កងទ័ព មកដល់បានមានការហាត់ក្បួនយុទ្ធសាស្ត្រជំនាន់ហ្នឹងហាត់មក ចលនាកាលហ្នឹងខ្លាំងណាស់ វ៉ៃ៧២-៧៣វ៉ៃខ្លាំងណាស់ ព្រោះកំលាំងតស៊ូគេគាំទ្រវ៉ៃខ្លាំង ហើយទាហានលន់ នល់ និយាយទៅពេលដែលគាត់វាតត្បាតទៅភូមិ ទាហានលន់ នល់ មានប្រើអំពើហិង្សា ឃោរឃៅវ៉ាស៊ីសជាទីបំផុត ការបាញ់ វាចង់បាញ់ជ្រូកស៊ីវាបាញ់ វាចង់បាញ់ឆ្កែស៊ីវាបាញ់ វាចង់បាញ់គោស៊ីវាបាញ់ វាចង់ធ្វើបាបអ្នកណាមួយវាធ្វើ មិនមែនមានសីលធម៌ល្អប្រពៃទេ ឃោរឃៅណាស់ទាហានលន់ នល់ ។ ដល់អីចឹងមានកំលាំងតស៊ូ និយាយពីរឿងការតស៊ូកំហឹងវណ្ណៈធ្វើម៉េចឈ្នះ បើឯងវាតត្បាត ទៅណាៗមានតែការកាប់សម្លាប់ មានតែហៅគ្រាប់ផ្លោងទម្លាក់បាញ់ចូលភូមិស្លាប់ប្រជាជន ហ្នឹងបានន័យថាវ៉ាស៊ីស ហើយខ្មែរឈាមជ័រខ្មែរដូចគ្នា ខ្មែរនិងខ្មែរដូចអូនឯងអីចឹង ។

ជ័យទត្តៈ ពេលហ្នឹងមកបាញ់សម្លាប់ បាញ់ជ្រូកប្រជាជន ទោះបីជាអត់ឃើញថាអ្នកហ្នឹងជាខាងខ្មែរ អត់គាំទ្រខ្លួនក៏បាញ់ដែរ?

រឿងៈ បាទ! គេបាញ់ ទាហានពីដើមគេហៅប៉ាត់ទីយុងខ្លះ ស្រុកឥឡូវយើងហៅអង្គភាពៗកងនេះ កងនោះ វាមានខ្លះឃោរឃៅ ខ្លះមានសីលធម៌ដែរ វាមិនមែនទាំងអស់ទេ ភាគច្រើន ឃោរឃៅ ភាគតិចណាស់គេនឹកឃើញខ្មែរ បងប្អូនគេ បងប្អូនឯង គេនឹកឃើញដែរ មិនទាំងអស់ទេ។

ជ័យទត្តៈ ពេលហ្នឹងទាហានលន់ នល់ ធ្វើខ្លះមានចាំទេ?

រឿងៈ ទាហានលន់ នល់ ឧទាហរណ៍ថាមេគេបញ្ជាថាមានខ្មែររំដោះលបវៃ លបបាញ់វា សុទ្ធតែរឿងធំហើយ វាចោទប្រជាជននៅភូមិហ្នឹងគាំទ្រពួកខ្មែរក្រហម។

ជ័យទត្តៈ ចោទមួយភូមិតែម្តង?

រឿងៈ ចោទ ចលនា ផ្លោងគ្រាប់ផ្លោងមកបាញ់ចូលភូមិប្រជាជន ទៅតវ៉ា និយាយពីរឿងការគ្រាប់ផ្លោងរបួសគោ ក្របី ស្លាប់រស់អីចឹង វាចាប់ផ្តើមវៃប្រជាជនឡើងហើមមុខ កាលហ្នឹងមានលោក ប្រធានភូមិទៅ មកវិញហើមអស់ហើយមុខ គេវៃ ហ្នឹងទាហានលន់ នល់ ហ្នឹងទាហានលន់ នល់ រួមជាមួយគេហៅយួនព្រៃនគរ យួនខាងត្បូង។

ជ័យទត្តៈ មកចូលរួម?

រឿងៈ ភាគច្រើនគេថាយួនខាងត្បូងហ្នឹងមក។

ជ័យទត្តៈ ពេលហ្នឹងប្រជាជនមានប្រតិកម្មអីទៅវិញជាមួយខាងលន់ នល់ ឬយួនខាងត្បូងទេ?

រឿងៈ មានដែរ ខ្លះគេតស៊ូ ខ្លះគេខឹងសម្បារគេកាប់ដែរ។ ការកាប់ហ្នឹងរួចខ្លួនកាប់ទៅវាបាញ់សម្លាប់។

ជ័យទត្តៈ កាប់ហ្នឹងកាប់ខាងណាវិញ?

រឿងៈ កាប់ ឧទាហរណ៍មានតាំបិត មានផ្គាក់ វាមកកាប់គោ គាត់ខឹងគាត់កាប់វិញទៅវាបាញ់ស្លាប់ ហើយវាចោទថាភូមិហ្នឹងចូលដៃ ចូលជើងជាមួយពួកខ្មែរក្រហម ខ្មែររំដោះ សម័យហ្នឹងយ៉ាប់ណាស់។

ជ័យទត្តៈ ខាងទាហានដែលវៀតណាមខាងត្បូងចូលមកនៅក្នុងដីខ្មែរយើងទេ?

រឿងៈ មកទាហានលន់ នល់។

ជ័យទត្តៈ ហៅមកតែម្តង?

រឿងៈ បាទ! អង្គភាពខ្លះសុទ្ធតែយួន។

ជ័យទត្តៈ ចុះស្លៀកពាក់ខោអាវ?

រឿន:	ស្បៀកពាក់ទាហានលន់ នល់ ហ្នឹង ។
ជ័យទត្ថៈ	តែជាវៀតណាមខាងត្បូង?
រឿន:	តែភាសាមិនមែនដូចខ្មែរយើងទេ ភាសាគេហៅប៉ៃឡាំៗ ភាសាដូចខ្មែរលើ ។
ជ័យទត្ថៈ	កាលហ្នឹងម៉េចខាងប្រជាជនដឹងថាខាងហ្នឹងជាវៀតណាម?
រឿន:	យើងដឹងថានេះកងទ័ពយួនខាងត្បូង គេដឹង ។
ជ័យទត្ថៈ	គេសំដៅមើលទៅលើម៉េចបានដឹង?
រឿន:	យើងដឹង ព្រោះកាលហ្នឹងមានការគាំទ្រពីយន្តហោះអឺចឹងយើងដឹង មានអាមេរិក យន្តហោះៗអាមេរិកកាំង ហើយលន់ នល់ ធ្វើរដ្ឋប្រហារហ្នឹងអាមេរិកគាំទ្រ ទៅជាចៅហ្វាយនាយ អឺចឹងមានយន្តហោះមកទម្លាក់ មានបេ៥២, ១១៦ អាពួកចានស្រាក់ ទ្រង់ជ្រូកបន្ទាកាត់ យន្តហោះវាឡើងពីព្រៃនគរមក ដូចបេ៥២ចុះនៅភ្នំពេញអត់កើត ឡើងពីព្រៃនគរមក ។
ជ័យទត្ថៈ	ពេលហ្នឹងយើងទីងខាងទាហាបលន់ នល់, ទាហានវៀតណាម យើងតដៃបានតែប្រើផ្កាក់?
រឿន:	ប្រើផ្កាក់ដល់ក្រោយមកប្រជាជនគាត់មានការឈឺចាប់ មិនដឹងរកវិធីអីដោះស្រាយ ពេលហ្នឹងគឺបន្ទុំកូន បន្ទុំប្តីឲ្យចូលតស៊ូ ព្រោះវាវេទនាពេកគេធ្វើបាបពេក បើអឺចឹងយើងចូលកងទ័ពតាមការអំពាវនាវរបស់សម្តេចនរោត្តមសីហនុ យើងក៏ចូលទៅព្រោះយើងស្រឡាញ់ស្តេច ។
ជ័យទត្ថៈ	ឆ្នាំណាពូ?
រឿន:	ឆ្នាំ១៩៧០-៧១-៧២ ។
ជ័យទត្ថៈ	ពូចូលពេលហ្នឹង?
រឿន:	ខ្ញុំចូល៧២ ។
ជ័យទត្ថៈ	បន្ទាប់ពីពេលចូលគេឲ្យពូធ្វើអីខ្លះ?
រឿន:	ចូលក៏ខ្ញុំចូលទ័ពតំបន់ ខាងចល័តភូមិភាគ ។
ជ័យទត្ថៈ	តំបន់អីគេ?
រឿន:	តំបន់៤១ ។
ជ័យទត្ថៈ	ភូមិភាគ?
រឿន:	ភូមិភាគឧត្តរ កាលហ្នឹងភូមិភាគធំណាស់ ទៅជាចល័តភូមិភាគឧត្តរ ហើយចាប់ផ្តើមបើកភូមិភាគវៃ ។ វៃព្រៃទទឹង, វៃស្គន់, វៃព្រែកក្តាម, វៃកោះគ្រឡាច, ខ្វាគ្រហឹម វៃច្រើនណាស់មួយជិនារហ្នឹង វៃទាហានលន់ នល់ និយាយពីដល់ស្លាប់និងរបួស ។

ជ័យទត្តៈ ពេលដែលពូចូលគេមានបង្រៀនអីខ្លះ?

រឿងៈ ហាត់បច្ចេកទេសវៃរបៀបផ្ការីក ឬវៃថ្នើរជើង ឬវៃបោកគ្រាប់បែក ។

ជ័យទត្តៈ ផ្ការីកគេវៃយ៉ាងម៉េចទៅ?

រឿងៈ ផ្ការីកគេវៃចូលពីក្នុងតែម្តង វៃចូលក្នុងបន្ទាយ គេហៅវៃពិសេស ។

ជ័យទត្តៈ ផ្សេងទៀតគេហៅយ៉ាងម៉េច?

រឿងៈ ផ្សេងទៀតវៃថ្នើរជើងរះ យើងស្ទាក់វៃ ឬយើងកន្ទ្រាក់មីន ចុចមីន វៃការពារមិនខុះទេពិធី ។

ជ័យទត្តៈ ចុះខាងណាគេបង្រៀនយើងយុទ្ធសាស្ត្រ?

រឿងៈ ខ្មែរយើងបង្រៀន អត់មានពីណាបង្រៀន មិនដឹងជាខ្មែរយើងចេះក្បួនយុទ្ធសាស្ត្រពីណាមក តាមការពិតយើងចេះយូរហើយក្បួនយុទ្ធសាស្ត្រ បើសម័យនោះដូចជានួន ជា គាត់ធ្លាប់តស៊ូតាំងពីជំនាន់អាណានិគមបារាំង គាត់ដឹងតាមក្បួនបច្ចេកទេស តាមមើលគាត់និយាយ ។

ជ័យទត្តៈ អ្នកណាអ្នកបង្រៀនពូ?

រឿងៈ ខ្ញុំ?

ជ័យទត្តៈ បាទ!

រឿងៈ ខ្ញុំបង្រៀនបច្ចេកទេសមិនដឹងណាអ្នកបង្ហាត់ តែខ្មែរយើង អាចគេចេះមកពីណា គេបង្រៀនបច្ចេកទេស វៃផ្ការីក វៃកន្ទ្រាក់មីន វៃថ្នើរជើង រួចគេមានវិធីបាញ់យន្តហោះ គេមានគ្រប់សព្វរបស់គេការវៃ គេមិនមែនដឹឡូងមូលណា គេវៃមានយុទ្ធសាស្ត្រច្បាស់លាស់ វៃផ្តាច់ផ្លូវ វៃផ្តាច់ស្ពាន ។

ជ័យទត្តៈ ក្រៅពីយុទ្ធសាស្ត្រហ្នឹងគេមានប្រាប់យើងវិធី ឬប្រាប់ពី ឧទាហរណ៍ថាយើងឃើញប្រជាជនឬមួយយើងត្រូវបែងចែកអាហារជាមួយប្រជាជនឲ្យច្បាស់?

រឿងៈ ហ្នឹងធម្មតាទេអូន យើងធ្វើសង្គ្រាម យើងមិនមែនវៃប្រជាជនទេ ព្រោះកងទ័ពវាកើតពីប្រជាជន បើអីចឹងធម្មតាសង្គ្រាមត្រូវការកំលាំងមនុស្ស អីចឹងវាអាចប៉ះពាល់ហើយវាមិនអាចអត់ប៉ះទេ ដូនកាលវៃតាមទីរួមស្រុក វៃតាមភូមិវាអាចប៉ះពាល់ខ្លះ បានន័យថាសង្គ្រាមវាប៉ះហើយ ហ្នឹងវាអីចឹង មិនមែនថាអត់ប៉ះទេ ។

ជ័យទត្តៈ មានខាងថ្នាក់ដឹកនាំគេមកបង្រៀន ពន្យល់យើងពីគេហៅទ្រឹស្តី?

រឿងៈ បាទ! រឿងទ្រឹស្តី ។

ជ័យទត្តៈ ទ្រឹស្តីហ្នឹងទ្រឹស្តីម៉េច?

រឿង៖ ទ្រឹស្ដីគឺយើង ទី១ យើងចង់និយាយពីតស៊ូវណ្ណៈ នាយទុន, សក្តិភូមិ គេហៅនាយទុនក្រៅប្រទេស នាយទុនជាតិឈ្មួញធំៗ នៅក្នុងស្រុកហ្នឹងវារកស៊ីកេងប្រវ័ញ្ចភោគផលប្រជាពលរដ្ឋ ឧទាហរណ៍ដូចទិញស្រូវ ទិញដំឡូង កសិផលរបស់ប្រជាពលរដ្ឋទិញថោកយកទៅលក់ថ្លៃ ហ្នឹងការរកស៊ី ការកេងប្រវ័ញ្ច ឬការទារពន្ធដារ ឬក៏ការកាប់សម្លាប់ ការកេងប្រវ័ញ្ច បើយើងនិយាយទៅតុលាការមិនប្រក្រតី តុលាការពុករលួយ ។ គេនិយាយសព្វបែបយ៉ាងទាំងអស់ដើម្បីឲ្យប្រជាជនយើងមានការឈឺចាប់ ហើយចូលរួមចលនារបស់ខ្លួនដើម្បីវិបក្រពត្តិ គេនិយាយសព្វបែបយ៉ាងរបស់គេណាស់ ។ ដល់និយាយទៅយើងឈឺចាប់ថាពួកអ្នកមានគេតកូនតចៅ វាធ្វើបាបប្រជាជន សង្កត់សង្កិត ជញ្ជក់យកផលរបស់កសិករមើលងាយមើលថោក ជាន់ឈ្លី គេហៅជាសត្វធាតុ សម័យនោះយើងឃើញមែនមិនមែនថាអត់ទេ ឃើញមែន គេអ្នកមានគេមិនចង់មើលយើងអ្នកក្រទេ គេសំដែងឫទ្ធិថាគេអ្នកមាន គេទៅជាមហាសេដ្ឋី គេជាកុងសី នាម៉ឺនអ្នកធំ ហ្នឹងយើងមើលឃើញពិតប្រាកដដល់អីចឹងចលនាវាមកនិយាយពីបញ្ហាហ្នឹងយើងមានកំហឹងឈឺចាប់ លះបង់ប្ដីសឹ លះបង់កូនចៅឲ្យចូលចលនាតស៊ូរបស់សម្ដេចឪយើងនេះ លោកបានអំពាវនាវតាមប៉ុស្តិ៍វិទ្យុជំនាន់នោះ ។

ជ័យទត្ត៖ លោកពូមានចាំទេថាមួយសប្ដាហ៍គេបង្រៀនអីចឹងៗ យើងប៉ុន្មានដង ឬមួយខែបង្រៀន?

រឿង៖ អត់ទេ គេហៅថាមានផ្លាស់មេរៀន ព្រោះយើងមិនអាចនៅរៀនបានយូរឆ្នាំ ឬក៏យូរខែទេ យើងថារៀន១-២ខែ ទៅវិម្ដង ហើយផ្លាស់អង្គភាពផ្សេងឲ្យមករៀនទៀត ព្រោះចលនាហ្នឹងថាឈានទៅមុខ ធ្វើឲ្យខ្មាំងបាក់ ដល់អីចឹងកំលាំង សភាពការណ៍វាវិវត្តន៍ជាប់មួយថ្ងៃទៅមួយថ្ងៃ មួយសប្ដាហ៍ទៅមួយសប្ដាហ៍វិវត្តន៍ជាប់ គេហៅថាជ័យជំនះ ខ្មាំងវិទាហានលន់ នល់ ស្រួលចង់ងាប់ ។

ជ័យទត្ត៖ ម៉េចបានមើលទៅវិស្រួល?

រឿង៖ វិស្រួលបានន័យថាទាហានខ្មែរអត់មានក្បួនយុទ្ធសាស្ត្រ ព្រោះប្រទេសយើងកើតសង្គ្រាមភ្លាមៗ វាត្រូវការចាប់បំពាក់អាវុធវិតែម្ដង ដូច្នេះការរៀនសូត្រគ្នាមិនបានទៅរៀនណាវែងឆ្ងាយទេ លើកលែងតែពួកបើកយន្តហោះ ឬពួកបាញ់កាំភ្លើងធំគេរៀនមែន បើទាហានលន់ នល់ ការបាញ់ត្រង់ណាស់ តាមយើងដឹងបាញ់ត្រង់ណាស់ តែការបាញ់ហ្នឹងវាគ្មានសន្សំសំចៃ យើងវិឈ្លបមួយប្រាវទាហានលន់ នល់បាញ់ទល់ភ្លឺអីចឹងចំណាយគ្រាប់ច្រើន ។

ជ័យទត្តៈ ពូនៅក្នុងអំឡុងពេលយើងរៀនទ្រឹស្ដីហ្នឹង គេមានប្រាប់យើងថាពីរបៀបខាងវៀតណាមគេចូលមកជួយខាងលន់ នល់?

រឿងៈ កាលហ្នឹងគេប្រាប់ដែរ ពេលហ្នឹងកំលាំងលន់ នល់ មានយួនព្រៃនគរមកជួយខាងលន់ នល់ ហើយយើងមានយួនខាងជើងចូលមកដែរ ។

ជ័យទត្តៈ ខាងយើង?

រឿងៈ មានដែរ ឆ្នាំ១៩៧១-៧២-៧៣ឃើញកងទ័ពយួនពេញតែស្រុកខ្មែរ ហើយយួនជួយរើអាហារលន់ នល់ ជាមួយកងទ័ពរំដោះដែរ ។

ជ័យទត្តៈ តែយួនហ្នឹងយួនខាងជើង?

រឿងៈ យួនខាងជើង ។

ជ័យទត្តៈ ពូដែលឃើញយួនខាងជើងនៅជាមួយពូទេ?

រឿងៈ មិនត្រឹមតែឃើញទេ បានសហការណ៍រើជាមួយគ្នាទៀត ។

ជ័យទត្តៈ យួនខាងជើងហ្នឹងនិយាយខ្មែរបានទេ?

រឿងៈ យួនខាងជើងដូចកំរមានចេះខ្មែរ និយាយរួមមិនចេះតែម្ដង ។

ជ័យទត្តៈ ចុះសហការណ៍គ្នាយ៉ាងម៉េច?

រឿងៈ មានថីបក មានជំនួយការគេមកសហការណ៍ជាមួយយើង ស។ដូចអូនអីចឹង ។

ជ័យទត្តៈ ពេលដែលគេបង្រៀនប្រាប់ពីទ្រឹស្ដីនៅក្នុងសម័យហ្នឹង តើគេប្រាប់យើងថាម៉េច? យើងធ្វើម៉េចជាមួយខាងវៀតណាម?

រឿងៈ យើងអត់ទាន់ដឹងថាយុទ្ធសាស្ត្ររបស់គេយ៉ាងម៉េចទេ គ្រាន់តែសហការណ៍គ្នាជួយរើជាមួយអាហារលន់ នល់ តែរឿងយុទ្ធសាស្ត្រគេយើងមិនបានដឹងទេសម័យហ្នឹង មានបងប្អូនវៀតណាមមកជួយអរ សប្បាយនិងគេដែរ ព្រោះគេមកជួយរើ គេសុខចិត្តចំណាយអាយុជីវិត គេសុខចិត្តចំណាយកំលាំងមកជួយរើអាមេរិក ពេលហ្នឹងយើងអរ សប្បាយដែរ គ្រាន់តែយុទ្ធសាស្ត្រទៅមុខ ទៅក្រោយសម័យហ្នឹងយើងអត់ទាន់ដឹងយ៉ាងណាទេ ។

ជ័យទត្តៈ ពូមានចាំទេអ្នកដែលមកបង្រៀនពូហ្នឹងគាត់ធ្វើអី?

រឿងៈ មកបង្រៀនហ្នឹងគេអ្នកបង្ហាត់បង្រៀនគេហៅគ្រូបង្ហាត់បង្ហឹកកងទ័ពឲ្យខាងរើក្បួនយុទ្ធសាស្ត្រ

ប្រុញៈ គាត់ឈ្មោះអីគេ?

រឿងៈ យើងមិនបានដឹងឈ្មោះគេទេ ថាឈ្មោះអីទេ ហៅលោកគ្រូ។ ។

ជ័យទត្តៈ តែយើងអត់ដឹងថាគាត់ជាកងទ័ព ឬគាត់ជាប្រជាជន?

រឿងៈ តាមការពិតគេខាងកងទ័ព គេរៀនយុទ្ធសាស្ត្រ យើងស្គាល់គេថាគ្រូ។ ។

ជ័យទត្តៈ គាត់ឈ្មោះអីគេអត់ប្រាប់យើងទេ?

រឿងៈ អត់ប្រាប់យើងទេ កាលពួកខ្មែរធ្វើមីន បច្ចេកទេសធ្វើមីន ធ្វើគ្រាប់ គេប្រាប់យើងឈ្មោះអី តែយើងថាលោកគ្រូ យើងទៅរៀនហៅលោកគ្រូៗ ។

ប្រុញៈ ពូថានួន ជា បង្រៀនៗពីអីគេ?

រឿងៈ នួន ជា កន្លងមកគាត់តែងនិយាយគាត់ចលនាតស៊ូ គាត់ថាសម័យគាត់មើលឃើញអាណានិគមបារាំងគេធ្វើបាបប្រជាជន ការធ្វើបាប ទារជីវិតពន្ធដាជំនាន់ហ្នឹង គាត់និយាយហែរៗមក ថាគាត់តស៊ូតាំងពីជំនាន់ប្រឆាំងអាណានិគមបារាំង ជំនាន់យូរហើយ ។

ជ័យទត្តៈ ពេលពូបានជួបគាត់ ជួបឆ្នាំណា?

រឿងៈ ជួបពីណាគេ?

ជ័យទត្តៈ ជួបអ៊ំនួន ជា?

រឿងៈ នួន ជា ជួបគាត់នៅអន្លង់វែង ។

ជ័យទត្តៈ តែជួបមុនពេលសម័យ៣ឆ្នាំ ឬមួយក៏?

រឿងៈ អត់ទេ ជួបឥឡូវៗ ជំនាន់៣ឆ្នាំយើងមិនអាចជួបបានទេ យើងមិនដឹងថាមេដឹកនាំខ្មែរក្រហមឈ្មោះអីផងទេ ទើបតែដឹងសម័យ៣ឆ្នាំ ។

ជ័យទត្តៈ តមកពេលឆ្នាំ៧២-៧៣ បន្ទាប់ពីពូបានចូលរួមនៅក្នុងសម័យបដិវត្តន៍ហើយ ពូបានចូលរួមប្រយុទ្ធនៅសមរភូមិណាខ្លះ?

រឿងៈ សម័យឆ្នាំ៧២ខ្ញុំបានវៃសមរភូមិច្រើនដែរ ទី១គឺសមរភូមិស្គន់ ព្រៃទទឹង តមកទៀតជើងព្រៃ តមកទៀតថ្នល់កែង សំបូរ សង្កើច ព្រែកក្ដាម ឡជីកង រហូតដល់ខ្សាគ្រហឹម កោះត្រឡាចលើ កោះត្រឡាចក្រោម ជ្រោយជង្វារ រហូតដល់ស្ពានព្រែកតាម៉ាក់ ស្ពានតាពេច ស្ពានតាមិន ខ្ញុំវៃតាមរោងចក្រកង់ រោងចក្រភួយ ។

ជ័យទត្តៈ វៃច្រើនសមរភូមិ?

រឿងៈ វៃច្រើនទល់មុខគីឡូលេខ៦ ឬ ទល់មុខឫស្សីកែវ ហៅវិហារចាម វៃតាមហ្នឹង ក៏ខ្ញុំរបួសចូលឆ្នាំ១៩៧៥ខ្ញុំរបួស វៃម្ដុំខាងកើតវិហារចាម ខាងកើតគីឡូលេខ៦ វិហារចាមវៃរបួសដេកពេទ្យជើងឆ្នុក បានគេបញ្ជូនមកកំពង់ធំ ដេកពេទ្យក្នុងព្រៃជំនាន់នោះ ។

ជ័យទត្តៈ ពូពេលមុនពូត្រូវរបួសប្រយុទ្ធក្នុងកំពង់ចាមដែរ?

រឿងៈ អត់ទេ នៅភ្នំពេញ ។

ជ័យទត្តៈ កៀកភ្នំពេញ?

រឿងៈ បាទ! កៀកភ្នំពេញ ។

ជ័យទត្តៈ ពេលសម័យនោះមាននាំប្រជាជនចេញពីកន្លែងតំបន់ប្រជុំជនទេ? មុនពួចូលមកដល់ភ្នំពេញ? សម័យម៉ុឆ្នាំ៧៣-៧៤?

រឿនៈ ពេលប្រជាជនជួនកាលខាងរដ្ឋអំណាចខាងលន់ នល់ គេជម្លៀសទៅមុន ឲ្យតែមានគេវ៉ៃប្រជាជនគាត់ចេញឯង ។

ជ័យទត្តៈ ចុះខាងរំដោះមានកៀរប្រជាជនខ្លះទេ?

រឿនៈ ខាងរំដោះ ជួនកាលប្រជាជនគេថាភ្នំពេញបានគេទៅភ្នំពេញ ទៅភ្នំពេញមិនបានគេរត់មកតំបន់រំដោះ បែងចែកគ្នា ហើយការប្រយុទ្ធគ្នាអត់មានប្រជាជនទេ មានខ្លះចាស់ៗគាត់ទៅរួចនៅចាំផ្ទះ ។

ជ័យទត្តៈ ពេលហ្នឹងបងប្អូនជនជាតិឥស្លាមនៅកំពង់ចាម គាត់ចូលខាងណា?

រឿនៈ ជនជាតិឥស្លាមខ្លះចូលទាហានលន់ នល់ ខ្លះចូលមកខាងយើងដែរ បងប្អូនឥស្លាមគគោកគជី

ជ័យទត្តៈ គាត់ចាម?

រឿនៈ ខ្មែរ-ឥស្លាម មានកងខ្ញុំគគោកគជី មានតាំងពីគួយ គេហៅជនជាតិ មានទំភួន ចារ៉ាយនៅជាមួយគ្នា នៅចំរុះទ័ព មានខ្មែរយើង មានបងប្អូនខ្មែរ-ឥស្លាម មានចារ៉ាយមានទំភួន មានភ្នង ចំរុះគ្នាកងទ័ព ហ្នឹងជាកងទ័ពអំពាវនាវរបស់ចលនា អីចឹងចំរុះគ្នា គេថាជនជាតិអីក៏ដោយឲ្យតែរួមក្នុងចលនាគេយកទាំងអស់ ។

ជ័យទត្តៈ ពេលសម័យហ្នឹងយើងអត់ទាន់មានការ ដូចថាបងប្អូនឥស្លាមយើងអត់ទាន់ធ្វើបាប បើខាងលន់ នល់ យើងអត់នេះទេ ឲ្យតែចូលរំដោះយើងយកទាំងអស់?

រឿនៈ និយាយរួមទាហានលន់ នល់ កាលហ្នឹងមិនមែនថាយើងចេះតែ គេមកសារភាពជាមួយគេយើងចេះតែសម្លាប់គេនោះទេ និយាយរួមមុនវ៉ៃ យើងត្រូវវ៉ៃហើយបន្ទាយហ្នឹងបើគេមកសារភាពជាមួយយើង យើងមានធ្វើអីគេ តែដល់ពេលវ៉ៃហើយ បាក់ទ័ពហើយធម្មតាទេយើងនៅជាមួយគេក៏គេមិនទុកចិត្តដែរ វ៉ៃបាក់ហើយបានឯងមកសារភាពហ្នឹងក៏គេមិនដែរ ហ្នឹងគេហៅកំហឹងវណ្ណៈ បើយើងមិនទាន់វ៉ៃគេមកយើងទទួលគេមក ស្វាគមន៍គេ បើវ៉ៃបាក់ហើយ វាទៅអួតថាខ្មែរមិនវ៉ៃខ្មែរ ខុសហើយ ។

ជ័យទត្តៈ ទោះបីជាសុំចុះចាញ់ហើយក៏ដោយ តែចាញ់ហើយទោះបីចូលមកសារភាព?

រឿនៈ ជួនកាលវាមានគ្នាច្រើន យើងវ៉ៃទៅគេលើកដៃ ក៏យើងអត់អាចសម្លាប់គេបានដែរ យើងនិយាយថាមួយបន្ទាយហ្នឹងមនុស្សមិនដូចគ្នាទាំងអស់ មួយបន្ទាយយើងវ៉ៃដាច់ទៅ មានរបាត់របាយមានខ្លះរបួសមកចូលទៅ ធម្មតាក្នុងសមរភូមិ ក្នុងបន្ទាយក៏គេមិនទុកដែរ បើសិនជារត់ចេញទៅក្រៅ ហ្នឹងគេទទួលយកដែរ ។

ជ័យទត្តៈ ហ្នឹងពូដែលឃើញផ្ទាល់ដែរ?

រឿងៈ បាទ! ឃើញផ្ទាល់ ។

ជ័យទត្តៈ ភាគច្រើនអ្នកដែលចាញ់គេបាក់ទ័ពរត់?

រឿងៈ បាទ! បាក់ទ័ពរត់ ។

ជ័យទត្តៈ ខ្វាត់ខ្វាយ?

រឿងៈ គ្នាច្រើនយើងទទួលយកដែរ មានកាំភ្លើងគ្រប់ទាំងអស់ ។

ជ័យទត្តៈ ខទាហរណ៍សុំចុះចូលហើយយើងអត់ទុកហ្នឹង ភាគច្រើនអ្នកហ្នឹងជាអ្នកប្រយុទ្ធផ្ទាល់ហ្នឹងសមរភូមិ?

រឿងៈ អ្នកប្រយុទ្ធផ្ទាល់ ឬក៏អ្នករបួស យើងកំពុងតែវ៉ៃគ្នាក្នុងបន្ទាយហ្នឹង ហ្នឹងមិនមែនសារភាពទេ ហ្នឹងប្រយុទ្ធស្លាប់រស់ជាមួយគ្នា ។

ជ័យទត្តៈ ចុះពេលចាប់បាន? កំពុងតែវ៉ៃៗចាប់បាន យើងដែលឃុំខ្លួន?

រឿងៈ ចាប់បានហ្នឹងខ្លះខឹងបាញ់ចោល ខ្លះគេមិនដឹងគេយកមក ។

ជ័យទត្តៈ ហ្នឹងកំហឹងទាហាន?

រឿងៈ ទាហាន ថាអីអាំ! កំលាំងអញគគោក ឯងវ៉ៃដាច់ហើយមិនសារភាព វាធម្មតាមនុស្សខុសគ្នា ។

ប្រុញៈ ពូនៅកងចល័តហ្នឹងកងចល័តឈ្មោះអីគេ?

រឿងៈ កងចល័តភូមិភាគ ។

ប្រុញៈ ភូមិភាគអីគេ?

រឿងៈ ភូមិភាគឧត្តរ ។

ប្រុញៈ ពីណាគេអ្នកកាន់ហ្នឹង?

រឿងៈ តាពក ។

ប្រុញៈ កែវ ពក?

រឿងៈ បាទ! កែវ ពក ។

ប្រុញៈ អីចឹងកែវ ពក កាន់ភូមិភាគ?

រឿងៈ បាទ! កាលហ្នឹងគាត់នៅភូមិភាគឧត្តរ គាត់នៅខាងភូមិភាគឧត្តរ កែវ ពក ហើយនិងតាឌុច ឃួន នយោបាយ ហើយតាពក យោធា កាលជំនាន់នោះ ។

ប្រុញៈ អីចឹងកងភូមិភាគហ្នឹងតាពក កាន់ផ្ទាល់តែម្តង?

រឿងៈ បាទ! ចល័តភូមិភាគឧត្តរ ។

ប្រុញៈ ពូបានជួបតាពក ញឹកដែរ?

រឿងៈ ជួបតែញឹក កាលប្រពន្ធគាត់ស្លាប់ក៏ជួបដែរ ។

ជ័យទត្តៈ ជួបក្រោយទេ? កាលពីសម័យមុនរំដោះអត់ជួប?

រឿងៈ សម័យមុនក៏ជួប ឧទាហរណ៍ថាគាត់ទៅបង្រៀន បើកយុទ្ធនាការវៃសមរភូមិគាត់ទៅ ទៅផ្សព្វផ្សាយពីរឿងសមរភូមិខ្មាំងសត្រូវបាក់គាត់ទៅ និយាយពីរឿងនយោបាយ មុននឹងវៃចូលសមរភូមិគាត់មានការប្រជុំ គាត់មានការធ្វើកម្មវិធី ឬការនិយាយពីរឿងសភាពចលនារបស់យើងវាឈានអីទៅ ខ្មាំងបរាជ័យគេនិយាយ ហើយបានយើងជ្រួតជ្រាបពីសភាពការណ៍បានយើងទៅវៃមិនមែនចេះតែបញ្ជូនទៅវៃទេ និយាយពីរឿងខ្មាំងសត្រូវចេះចុះ

ប្រុញៈ តាពក គាត់និយាយពីរឿងខ្មាំងចង់សំដៅទៅពីណាខ្លះ?

រឿងៈ ខ្មាំងហ្នឹងខ្មាំងលន់ នល់ ។

ប្រុញៈ ហ្នឹងក្នុងឆ្នាំណា?

រឿងៈ យើងនិយាយក្នុងឆ្នាំដែលក្រោយពីលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច គេហៅសភាពការណ៍ពេលហ្នឹងខ្មាំងសត្រូវគឺអាមេរិក ។

ប្រុញៈ ហ្នឹងក្នុងកំឡុងឆ្នាំ?

រឿងៈ ឆ្នាំកំពុងចលនាវៃគ្នាហ្នឹង ។

ប្រុញៈ អត់ទេ ពូចូល៧២ត្រូវទេ?

រឿងៈ បាទ! ៧២ ។

ជ័យទត្តៈ បើពូប្រជុំជាមួយ?

រឿងៈ ៧២ហ្នឹងវាចលនាហ្នឹងមិនមែនកើត៧២ទេ ចលនាវាកើតតាំងពីឆ្នាំមួយពាន់ប្រាំបួនរយហុកប៉ុន្មាននោះ គ្រាន់តែចលនាពេលហ្នឹងវាគគ្រឹកគគ្រេង មានកងទ័ពវៃទៅជាទ្រង់ទ្រាយមានខ្សែចង្វាក់ ឯចលនាវាកើតយូរហើយ ចលនាបដិវត្តន៍ គេហៅគណបក្សប្រជាជនយូរហើយ តាំងពីជិនាន់អាណានិគមបារាំងតស៊ូ មិនមែនឥឡូវទេ តែពេលហ្នឹងដែលលន់ នល់ទម្លាក់សម្តេចនរោត្តមសីហនុពីអំណាច ពេលហ្នឹងគេហៅថាមានទ័ពប្រឈមមុខនឹងលន់ នល់ខាងខ្មែររំដោះ ទៅជាមានភាគី យើងមើលឃើញមានភាគីនេះ ភាគីនោះ មានការគាំទ្រគាំភ្លើងធំពីអាមេរិក យើងបានដឹងកប៉ាល់ហោះ ខ្ញុំវៃជាមួយលន់ នល់ ផ្ទាល់ហើយមានកងអន្តរាគមន៍យន្តហោះ ស្អីក៏មានដែលជិនាន់ហ្នឹង ។

ជ័យទត្តៈ តាមពូចាំសម័យមុនរំដោះឆ្នាំ៧២ដែលពូចូលទៅក្នុងចលនាបដិវត្តន៍ ហើយរហូតដល់មុនរំដោះថ្ងៃ១៧ មេសា ពូធ្លាប់បានរៀនទ្រឹស្តីប៉ុន្មានដង?

រឿងៈ	បានរៀនច្រើន ព្រោះពេលហ្នឹងក្រោយពី១៧ មេសា មកគឺពួកខ្ញុំត្រូវបញ្ចូលទៅកងមជ្ឈិម ខ្ញុំនៅកងមជ្ឈិម៤៥០ ឈ្មោះលោក អ៊ិត សួង ដែលប្រធានកងពល៤៥០ អ៊ិត សួង ។

ជ័យទត្តៈ	អ៊ិត សួង?

រឿងៈ	អ៊ិត សួង ។

ជ័យទត្តៈ	ពេលហ្នឹងគាត់មានបង្រៀនពូពីអីខ្លះ?

រឿងៈ	គាត់និយាយពីរឿងសភាពការណ៍ដូចអង្គការខាងលើបានផ្សព្វផ្សាយដែរ ក៏ប៉ុន្តែគាត់គេហៅថាមានខ្លះដែលគាត់ចេញសំដែងជាអកប្បកិរិយា ឬសកម្មភាព ។

ជ័យទត្តៈ	សកម្មភាពម៉េចទៅ?

រឿងៈ	សកម្មភាពទី១ គេចង់និយាយថាពេលដែលកងទ័ពធ្វើដំណើរទៅមានគ្រាប់ផ្លោងមក ពេលដែលមិនទាន់មានការប្រជុំ មានការវ៉ៃគ្នាមិនមានគ្រាប់ផ្លោងមក ដល់ពេលមានផែនការបញ្ជូនកងទ័ពចូលខ្សែត្រៀមស្រាប់តែមានគ្រាប់ផ្លោងចូលមក ហ្នឹងជាសកម្មភាព ហៅគ្រាប់ផ្លោងមក ។ កាលហ្នឹងខ្ញុំនៅកំពុងជ្រៃ១០០យើងនេះ ចន្ទ្រានបាយនៅជ្រៃ១០០ហ្នឹង ពេលប្រជុំជួរធ្វើដំណើរកងទ័ពកាត់ទឹក កាលហ្នឹងទឹកមិនទាន់ស្រកផុតណាំ ទឹកវាស្រកទៅហើយតែវាមិនទាន់ស្រកចុះ យើងត្រូវធ្វើដំណើរកាត់បឹង គេហៅម្តុំបឹងខាងកើតព្រែកលៀបមានបឹង គេហៅបឹងឫស សុទ្ធតែបឹងហើយ យើងធ្វើដំណើរកាត់បឹងហ្នឹងស្រាប់តែមានគ្រាប់ផ្លោងមក ដល់អីចឹងយើងមើលឃើញសកម្មភាព ខាងលើក៏តាមដានដែលសកម្មភាពរបស់កងពលហ្នឹង ។

ជ័យទត្តៈ	តែមេដែលឈ្មោះ អ៊ិត សួង?

រឿងៈ	បាទ!

ជ័យទត្តៈ	សកម្មភាពហ្នឹងបើសិនជាធម្មតាគេហៅយ៉ាងម៉េច?

រឿងៈ	សកម្មភាពហ្នឹងគេថាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ហើយថ្នាក់ដល់កងពលទៀត ។

ជ័យទត្តៈ	ចុះបន្ទាប់មកឈ្មោះ អ៊ិត សួង ហ្នឹងគេចាប់បានទេ? សកម្មភាពហ្នឹងវាការពិត?

រឿងៈ	អ៊ិត សួង ហ្នឹងគឺសម័យប៉ុល ពត គេចាប់គាត់នៅឆ្នាំ១៩៧៧តាមខ្ញុំដឹង ព្រោះកាលហ្នឹងក្រោយពី១៧ មេសា យើងត្រូវបានរំដោះហើយហ្នឹងគឺ ឆ្នាំ១៩៧៦ គឺប៉ុល ពត គាត់នឹងប្រកាសផ្តាច់ខ្លួនពីឥណ្ឌូចិន ចូលនយោបាយហើយ ពេលហ្នឹងខ្ញុំដឹងព្រោះកងមជ្ឈិមពេលហ្នឹងខ្ញុំធ្វើមេដែរ មិនមែនកូនទាហានសុទ្ធណា ខ្ញុំធ្វើមេដែរ គេហៅទៅរៀន ។

ជ័យទត្តៈ	នៅក្នុងអីគេធ្វើហ្នឹង?

រឿងៈ	នៅក្នុងឆ្នាំ១៩៧៥-៧៦ហ្នឹងគឺប៉ុល ពត ត្រូវប្រកាសខ្លួនគាត់ទៅជាលេខាបក្ស ។

ជ័យទត្តៈ ពូចាំថ្ងៃ ខែទេ?

រឿនៈ យើងអត់ដឹងថាខែណា ខ្ញុំមិនបានចាប់អារម្មណ៍ព្រោះប្រកាសតាមវិទ្យុ ហើយកាលទៅទទួលសម្តេចនរោត្តមសីហនុដែលលោកយាងចូលស្រុកក៏ខ្ញុំទៅទទួលដែរ គេប្រកាសតែងតាំងបក្សក៏ខ្ញុំបានទៅដែរ ប្រកាសប៉ុល ពត ឡើងលេខាបក្ស ប៉ុល ពត អត់បានទៅទេ តែលោកខៀវ សំផន ទៅតំណាង ស្តាតអូឡាំពិកយើងនេះ ។

ជ័យទត្តៈ ប្រកាសតែងតាំងលេខាបក្សហ្នឹងអវត្តមានលេខាហ្នឹងវិញ?

រឿនៈ បាទ! លេខាអត់មកទេ ប៉ុល ពត អត់មកទេ ។

ជ័យទត្តៈ អ្នកណាអ្នកមកជំនួស?

រឿនៈ ខៀវ សំផន តាមការពិតដែនការកាលហ្នឹង បើសិនជាប៉ុល ពត អញ្ជើញមកក្នុងកម្មវិធីហ្នឹងប៉ុល ពត ត្រូវគេធ្វើរដ្ឋប្រហារហើយ តែគាត់ដឹងខ្លួនគាត់អត់មក ត្រូវតែងតាំងមនុស្សផ្សេងមកជំនួស ហើយកងទ័ពសុទ្ធតែកាំភ្លើង សុទ្ធតែមានគ្រាប់ទៀត កាលហ្នឹងកងគេហៅពួកចក្រី ។ ពួកចក្រីហ្នឹងពីដើមម៉ិញនៅខាងបូព៌ា ប្រហែលពួកចក្រី ។

ជ័យទត្តៈ ឈ្មោះអីចក្រី?

រឿនៈ មិនដឹងឈ្មោះអី គេហៅតែចក្រីៗអីចឹងម្តង កងពលហ្នឹងសុទ្ធតែមានកាំភ្លើង កាលណាប៉ុល ពតគាត់មកប្រកាសឡើងលេខាបក្ស បុគ្គលណាដែលឡើងលេខាបក្ស ពេលហ្នឹងគេត្រូវធ្វើរដ្ឋប្រហារ តែពេលហ្នឹងគាត់អត់មកគេដឹង ដល់អីចឹងគេត្រូវចាប់ខ្លួន ។

ជ័យទត្តៈ ម៉េចបានពូបានដឹង?

រឿនៈ មិនដឹងម៉េចខ្ញុំរៀន ។

ជ័យទត្តៈ ខាងណាអ្នកប្រាប់?

រឿនៈ ខ្ញុំនៅកងពលស្លួង ដែរ ព្រោះកងពលហ្នឹងធ្វើចលនាប្រឆាំងជាមួយរបបប៉ុល ពត ដែរ ។

ជ័យទត្តៈ ចុះស្លួង ហ្នឹងគាត់មានខ្សែរយៈគាត់ជាមួយខាងណា?

រឿនៈ តាមការពិតមិនមែនជាឯកសារទេ គ្រាន់តែពាក្យចចាមអារាមទេ ហើយយើងពេលហ្នឹងកងទ័ពខ្មែរក្រហមទៅរៀន ភាគច្រើនមិនចេះអក្សរទេ មិនដឹងគេរៀនចង់និយាយពីអីទេ អូនឯងគិតម៉េចគ្នា២០០-៣០០នាក់ រកមនុស្ស២-៣នាក់ធ្វើប្រវត្តិរូបមិនបានឃើញទេ គឺថាភាគច្រើនមិនចេះអក្សរ បើអីចឹងការរៀនសូត្រគេដាក់ថ្ងៃ ដាក់ខែ ទាំងអស់តែយើងមិនចេះសរសេរ គ្រាន់តែយើងចេះស្តាប់ ។ មនុស្សខ្លះអត់ចេះអក្សរតែគេនិយាយមកយល់ហើយ?

ជ័យទត្តៈ បាទ!

រឿង: ហ្នឹងយើងអីចឹង ហើយខ្ញុំកាលហ្នឹងរៀនថ្នាក់ទី១០ ខ្ញុំមិនទាន់ចេះអក្សរអីប៉ុន្មាននៅល្ងង់ដែរ ដល់អីចឹងការរៀនសូត្រ សកម្មភាពនៃខែនេះ ឆ្នាំនេះគេដាក់ទាំងអស់ មិនមែនគេមិនដាក់ឯណា ។

ជ័យទត្ត: ខាងណាអ្នកប្រាប់ពូ អ្នកបង្រៀនពូ?

រឿង: ហ្នឹងខាងអគ្គសេនាធិការគេ គេចាប់ខាងណា គេហៅមេដឹកនាំទៅរៀន ឬហៅមេទាហានល្មមៗដូចជាអនុសេនាតូច អនុសេនាធំ វរសេនាធំ វរសេនាតូចទៅរៀន ជួនកាលគេរៀនមួយអង្គភាពតែម្តង នេះសកម្មភាពកងពលនេះវាធ្វើវិធសិណា វាបង្កត់បាយកងទ័ព វាឲ្យកងទ័ពហូបបបរ ពេលឈឺគ្រុនវាមិនមើលទុកឲ្យកងទ័ពស្លាប់ នេះជាសកម្មភាពរបស់ខ្មាំងស៊ីរូងផ្ទៃក្នុងនៅក្នុងជួររបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ឬនៅក្នុងក្រសួង ឬនៅក្នុងមន្ទីរ ឬនៅក្នុងមូលដ្ឋានគេនិយាយទាំងអស់ ។

ជ័យទត្ត: ពូនៅចាំទេអគ្គសេនាធិការហ្នឹងខាងណាអ្នកគ្រប់គ្រង?

រឿង: អគ្គសេនាធិការហ្នឹងរបបប៉ុល ពត គ្រប់គ្រង ទៅរៀនកន្លែងអគ្គ មានឈ្មោះណាត តាអីៗ ។

ជ័យទត្ត: ឈ្មោះណាត?

រឿង: ស្អីណាតទេ រៀននៅកំពង់ឆ្នាំង ។

ជ័យទត្ត: នៅខាងណាកំពង់ឆ្នាំង?

រឿង: មករៀនកំពង់ឆ្នាំង កាលហ្នឹងគេត្រូវបញ្ជូន ព្រោះចេះប៉ុល ពត តាមការពិតឆ្នាំ៧៦-៧៧-៧៨ កងខ្ញុំប៉ិនប៉ងធ្វើរដ្ឋប្រហារប៉ុល ពត ដល់៦ដង ។

ជ័យទត្ត: កងរបស់ពូ?

រឿង: បាទ! តែរួមគ្នា មិនមែនតែកងខ្ញុំទេ កងខ្ញុំ៤៥០ មានកង៣១០ មានកង៥០២ខ្លះ ៥០២គេនៅខាងពោធិ៍ចិនតុង ខាងកងរថក្រោះ កងយន្តហោះ និយាយរួមគ្រប់កងពល ។

ជ័យទត្ត: ប្រហែលប៉ុន្មានកងពលពូចាំទេ?

រឿង: មើលកងពលគ្រាន់តែកងពលមជ្ឈឹមមានកងពល៨០១, កងពល៨០២របស់តាសារឿន គេហៅកងពលទី២ ។

ជ័យទត្ត: ឈ្មោះអីសារឿន?

រឿង: ស្អីសារឿន គេហៅ០៥ គេហៅបងសារឿន ។

ជ័យទត្ត: ហើយក្រៅ០៥?

រឿនៈ ហៅគាសារឿន ក្រោយមកហៅតា០៥ នៅខាងរតនគិរី ពេលដែល៧៦-៧៧ក៏មកដែររតនគិរី ក៏មកធ្វើរដ្ឋប្រហារដែរ តែមកខាងគណៈ៨៧០ កន្លែងប៉ុលពតគេដឹងដែនការគេអត់ឲ្យសាឡាងឆ្លង កាលហ្នឹងមានណាស្ពានជ្រោយចង្វារដាច់ហើយហ្នឹង មានសាឡាងឆ្លងអត់មានស្ពាន ដល់អីចឹងគេឲ្យទៅវិញ គេចាប់ផ្ដើមចាប់ៗ និយាយរួមជុំវិញកន្លែងអគ្គសេនាធិការ កន្លែងទីបញ្ជាការ ហៅមេបញ្ជាការចាប់ទាំងអស់ ចាប់តាមបុគ្គល បុគ្គលណាដែលក្បត់គេចាប់ បុគ្គលណាដែលអត់ក្បត់គេអត់ចាប់ៗ

ជ័យទត្តៈ កងពលពូអ្នកដឹកនាំឈ្មោះអី?

រឿនៈ អ៊ិត សួងៗ

ជ័យទត្តៈ ក្រោយមកគេចាប់គាត់?

រឿនៈ គេចាប់គាត់ៗ

ជ័យទត្តៈ ពូមានដឹងគេបន្ទាប់ពីចាប់ហើយគេយកគាត់ទៅណា?

រឿនៈ យើងមិនដឹងថាគេយកទៅណាទេ ព្រោះគេថ្នាក់កងពល យើងគ្រាន់តែជាមេទាហានល្មមៗយើងមិនអាចដឹងបាន គ្រាន់តែថាគេចាប់ហើយៗ

ប្រុញៈ ពូប្រធានអីគេ?

រឿនៈ ខ្ញុំ?

ប្រុញៈ បាទៗ

រឿនៈ ខ្ញុំប្រធានអនុសេនាធំៗ

ជ័យទត្តៈ ខាងណា?

ប្រុញៈ ប្រធានអនុសេនាធំ?

រឿនៈ ប្រធានអនុសេនាធំៗ

ជ័យទត្តៈ កាន់ប៉ុន្មាននាក់ពូ?

រឿនៈ ១២០នាក់ជាង ព្រោះមួយកងតូចវា៣២នាក់ ៣កងតូចវាមួយអនុសេនាធំ វាស្មើរនឹង១២០នាក់ៗ

ជ័យទត្តៈ នៅពេលគេចាប់មេពូគេមានដែលមកស្រាវជ្រាវអ្នកនៅក្រោម?

រឿនៈ បាទ! ស្រាវជ្រាវ គេចាប់បន្តៗទៀតៗ

ជ័យទត្តៈ ចាប់អ្នកដែលពូស្គាល់?

រឿនៈ បាទ! ស្គាល់អ្នកនៅកងជាមួយគ្នាយើងស្គាល់ កងខុសគ្នាយើងអត់ស្គាល់ៗ

ជ័យទត្តៈ ចាប់អស់ប្រហែលប៉ុន្មាននាក់ ចាំទេ?

រឿង: ចាប់អស់ច្រើន យើងអត់ដឹងថាអ្នកណាប៉ុន្មាននាក់ ចាប់អស់ច្រើន អីចឹងបានថាខ្ញុំវាមិនបាន ចាប់អារម្មណ៍ ។

ជ័យទត្ត: គៀកៗ នៅជិតពូប៉ុន្មាននាក់? ដែលគេចាប់យកទៅពូមានដឹងទេ?

រឿង: ចាប់អស់ច្រើន មួយកងវរសេនាធំចាប់៦-៧នាក់ គេចាប់នោះចាប់ គេដឹងសកម្មភាពចាប់ យកទៅសួរចម្លើយបានធ្វើអីខ្លះកន្លង ហើយបានកសាងកំលាំង ហើយគេចាប់បន្តទៀត ចាប់ច្រើនមែនទែន ។

ជ័យទត្ត: ពូកាលហ្នឹងអត់អីទេ?

រឿង: យើងអត់អីទេ យើងមិនបានគេបំពាក់បំប៉នទៅជាភ្នាក់ងារ គ្រាន់តែនៅក្នុងកងហ្នឹង អ្នកណា ការងារម៉ឺងម៉ាត់គេអត់ហ៊ានជាមួយយើងទេ គេចាត់តាំងតែមនុស្សសេរី មនុស្សខ្ជិល ការងារហ្នឹងគេចាត់តាំងហើយ មនុស្សយើងធ្វើការងារម៉ឺងម៉ាត់គេអត់ចាត់តាំងទេ ។

ជ័យទត្ត: តែពូដឹងថាកងពូកាលហ្នឹងត្រៀមខ្លួនដើម្បីផ្តួលរំលំប៉ុល ពត?

រឿង: មានផែនការវៃ ចាំមើលកងខ្ញុំ កងពលរបស់អ៊ិត សួង មានកងពលលេខ៤៥០ គាត់ លោកអ៊ិត សួង គាត់មានសកម្មភាពត្រៀមកាំភ្លើងទុកលើវិហារចាមមុំប្រាំងចំរេះ ទុកលើ វិហារចាមកាំភ្លើងគាត់លាក់នៅហ្នឹង រួចកងសេអ៊ឹមសេ១២គ្រឿងគាត់អត់មានដាក់ស្លាក លេខទេគាត់បាញ់ថ្នាំថ្មីចេស សំរាប់ដឹកកងពិសេស កាលហ្នឹងខ្ញុំនៅកងពិសេស២០៩របស់ ពិសេសកងពល៤៥០ហ្នឹង សំរាប់ធ្វើសកម្មភាពពីត្រឹមឬស្សីកែវមកព្រែកព្នៅ ហើយគាត់ មានលាក់កាំភ្លើងទុក លាក់គ្រាប់ទុក គ្រាប់១០៥គាត់ដាក់នៅព្រែកព្នៅ២ដើមមានគ្រាប់ ដល់ទៅ៥០០០គ្រាប់ ប្រុងរួមគ្នាវៃភ្នំពេញ ចៃដន្យគេហៅ វាចេះតែបែកការណ៍ ចាប់ កងនេះ ចាប់កងនោះ ដូច្នេះផែនការហ្នឹងវាបរាជ័យ ។

ជ័យទត្ត: ឆ្នាំណា?

រឿង: ឆ្នាំ៧៧ ។

ជ័យទត្ត: គំរោងវៃ?

រឿង: បាទ! គំរោងវៃភ្នំពេញតែវាមិនឯកភាពគ្នាការវៃ បើមេក្បត់ខ្លះៗ អីចឹងចាប់កងនេះ ចាប់ កងនោះ ទៅមានលាក់កាំភ្លើងទុក ដូចខ្ញុំនិយាយម៉ិញអីចឹង គ្រាន់តែគ្រាប់ដេការ៧៥ ខ្លះអី គ្រាប់ដេការ៧៥ទាហានលន់ នល់អត់បានប្រើ ខ្លះអីគ្រាប់បេ៤១នៅភ្នំពេញ ទាហានលន់ នល់គេអត់ប្រើ គេប្រើសុវណ្ណភូមិ បើអ៊ឹម៧៩ ប្រើអ៊ឹមសី អាការមិនសូវមានអ្នកប្រើទេ ទុកពេញៗឃ្លាំងទាំងអស់ ។

ជ័យទត្ត: ពេលហ្នឹងគេប្រាប់ពូថាផែនការគេមានហើយ?

រឿង៖ គេអត់ប្រាប់យើងទេ គេលើកឡើងថាជិតឃើញសំបុកថ្មី របបថ្មី គេនិយាយអីចឹង គេគ្រាន់តែនិយាយអីចឹងទេ ចំពោះមនុស្សដែលមើលថាការងាររម៉ឺងម៉ាត់ ហើយអ្នកនោះចេះទ្រឹស្តី ការងារមិនសូវកំប៉ិកកំប៉ុក ថាការងារបក្សប្រគល់ឲ្យធ្វើគេគិតតែធ្វើ អ្នកដែលបំពាក់បំប៉នជាក្អាក់ងាររបស់គេ គេអត់ធ្វើជាមួយយើងទេ គេធ្វើជាមួយមនុស្សណាសេរី ព្រោះរបបសេរីគេត្រូវការមនុស្សសេរី របបកុំមុយនីស្តគេមិនចូលចិត្ត មនុស្សសេរី ។

ជ័យទត្តៈ ពូមានចាំថាមនុស្សដែលគេចាប់ទៅទាំងប៉ុន្មានមានដែលត្រឡប់មកវិញទេ?

រឿង៖ មិនដែលឃើញត្រឡប់មកវិញទេ គេចាប់យកទៅដាក់គុក ឃ្នាងខ្នោះ តែការសម្លាប់យើងមិនដឹងថាគេយកទៅសម្លាប់ឯណាទេ តែមានបាត់មនុស្ស សូម្បីតែនិយាយមិនទទួលខុសត្រូវក៏ត្រូវបាត់ដែរ សូម្បីតែស្ងួងស្រូវក៏គេដកមើលដែរ ថាយើងស្ងួងម៉េច ។

ជ័យទត្តៈ ប៉ុន្តែពេលបន្ទាប់ក្រោយមកទៀតពូមានដឹង ក្រោយរបបពាឆ្នាំពូមានដឹងថាបាត់ហ្នឹងគេយកទៅណា?

រឿង៖ យើងមិនដឹងថាគេយកទៅណាទេ ដឹងតែស្លាប់ហើយ មិនអាចយកទៅណា ទុកឲ្យរស់មានជីវិតទេ ព្រោះហ្នឹងគេចាប់ទៅសុទ្ធតែស៊ើបអង្កេតច្បាស់ណាស់ សកម្មភាពច្បាស់ណាស់ ព្រោះសកម្មភាពយើងបាននិយាយ គេឲ្យស្ងួង គេឲ្យរួមចំឡែកធ្វើស្រែព្រោះប្រទេសយើងក្រ ចប់ពីសង្គ្រាមទៅ កងទ័ពត្រូវជួយធ្វើស្រែ ហ្នឹងសកម្មភាពគេមើលតាមហ្នឹងគេដឹងហើយ ។

ជ័យទត្តៈ ពូកាលហ្នឹងអ្នកណា អ្នកបញ្ជាឲ្យចាប់ខ្លួន?

រឿង៖ ហ្នឹងគេហៅថាបក្សបញ្ជាឲ្យចាប់ កាលហ្នឹងគេហៅអង្គការថ្នាក់លើ ។

ជ័យទត្តៈ បើតាមពូៗយល់ថាអង្គការថ្នាក់លើ អ្នកណាអ្នកគ្រប់គ្រងខាងហ្នឹង?

រឿង៖ អង្គការខាងលើចង់និយាយថារកអង្គការមិនឃើញទេ អង្គការមិនដឹងជាមួយណាទេ បុគ្គលណាទេអង្គការ បើគេថាអង្គការថ្នាក់លើ អីចឹងអង្គការថ្នាក់លើកំពូលហើយ ។

ជ័យទត្តៈ បើពូស្គាល់អ្នកកំពូលៗមានពីណាខ្លះ? ពូមានស្គាល់ទេកាលសម័យហ្នឹង?

រឿង៖ សម័យនោះគេប្រកាសខ្លួន ប៉ុល ពត ជាលេខាបក្ស សមមិត្តលេខាប៉ុល ពត ជាអ្នកប្រឈមមុខ ។

ជ័យទត្តៈ ក្រៅពីគាត់មានអ្នកណាខ្លះទៀត?

រឿង៖ យើងដឹង យើងស្គាល់ មានសុន សេន ។

ជ័យទត្តៈ អ្នកណាទៀត?

រឿង៖ ប៉ុល ពត លេខាបក្ស បន្ទាប់មកមាន នួន ជា, សុន សេន ក្រសួងការពារជាតិ, អៀង សារី ក្រសួងការបរទេស យើងដឹង ។

ជ័យទត្ត៖ អ្នកផ្សេងៗទៀត?

រឿង៖ និយាយរួមគ្រប់ក្រសួងទាំងអស់ ។

ជ័យទត្ត៖ អ្នកដែលពូស្គាល់?

រឿង៖ អ្នកដែលខ្ញុំស្គាល់ច្បាស់មែនទែន មានតែប៉ុល ពត, តាម៉ុក, ខៀវ សំផន, នួន ជា, វ៉ន វ៉េត, សោ ភឹម ខ្ញុំស្គាល់ ហេង សំរិន, ជា ស៊ីម ក៏ខ្ញុំស្គាល់សម័យនោះ មិនមែនខ្ញុំមិនស្គាល់ទេ ខ្ញុំស្គាល់គាត់នៅបូព៌ា ហេង សំរិន, ជា ស៊ីម គាត់នៅបូព៌ា ។

ជ័យទត្ត៖ ពូស្គាល់គាត់តាមរយៈអី ពូមានចាំទេ?

រឿង៖ កាលហ្នឹងខ្ញុំមជ្ឈឹម ប៉ុល ពត គេបញ្ជូនទៅវៀយួននៅហ្នឹង នៅបូព៌ាហ្នឹង ខ្ញុំស្គាល់តាំងពីយាយ តារ៉ូ ប្រពន្ធជា ស៊ីម, ស្គាល់ពួក០៩គគោកសហករណ៍គ្នាវៀយួន ។

ជ័យទត្ត៖ ដោយសារតួនាទីពូជាអនុ?

រឿង៖ កាលហ្នឹងខ្ញុំគេអត់មានតួនាទីអីទេ ជាកូនទាហាន ព្រោះគេដឹងថាយើងនៅក្នុងកងពល៤៥០ ដាច់ភ្នំពេញ គេដឹងថាមេយើងក្បត់កងក្បត់ ពេលហ្នឹងគេទម្លាក់តំណែងយើងហើយទៅជាយុទ្ធជនធម្មតាហើយខំកសាងខ្លួន ។ ដល់ពេលឆ្នាំ៧៦-៧៧ដែលកម្ពុជាប្រជាធិបតេយ្យជាមួយវៀតណាមដោះស្រាយគ្នាមិនត្រូវ រឿងដែលហៅថាកម្មវិធីរឿងទំនាស់អីៗរហូតដល់អគ្គរាជទូតដោះស្រាយមិនត្រូវវៃគ្នា ពេលហ្នឹងពួកបូព៌ាវៃជាមួយគ្នា ក្រោយមកបានមានការបែកបាក់គ្នារឿងក្បត់ ។

ជ័យទត្ត៖ ពូពេលគេឲ្យពូឡើងប្រធានអនុសេនាធំឆ្នាំណាវិញ?

រឿង៖ ខ្ញុំឡើង៧៥ ។

ជ័យទត្ត៖ ក្រោយមកបានគេដកពូ?

រឿង៖ ដល់៧៥កងក្បត់គេដកសិទ្ធិយើងចេញនៅជាទាហានធម្មតា ។

ជ័យទត្ត៖ ក្រោយមកគេបញ្ជូនពូទៅវៃ?

រឿង៖ គេបញ្ជូនខ្ញុំទៅធ្វើស្រែ ធ្វើស្រែនៅម្តុំក្រាំងធ្នង់ក្បែរពោធិ៍ចិនតុង, ព្រៃសំរោង, តាំងក្រសាំង ទំនួចពុលខ្ញុំនៅម្តុំហ្នឹង ដល់ទាហានកងពល៤៥០ឲ្យកងទ័ពដឹងភូមិសាស្ត្រ និយាយរួមតាំងពីខ្ញុំស្គាល់ភូមិសាស្ត្រ តាំងពីខាងកើតគីឡូលេខ៦រហូតដល់ព្រែកព្នៅ អន្លង់ក្ងាន រហូតដល់ពោធិ៍ចិនតុងខ្ញុំស្គាល់ទាំងអស់ភូមិសាស្ត្រ ដូចនេះវាឲ្យស្គាល់ភូមិសាស្ត្រ ជំនាន់ហ្នឹងអត់មានផ្ទះទេ សុទ្ធតែបឹង ដើម្បីត្រៀមវៃប៉ុលពតនៅឆ្នាំ១៩៧៧ ប៉ុលពតគេត្រូវវៃ តែការវៃហ្នឹងមិន

ឯកភាពគ្នាក្នុងការវ៉ៃ ដល់ហើយប៉ុល ពត ចាប់ផ្ដើមបញ្ហាចាប់កងនេះ ចាប់កងនោះ ចាប់ ហើយគេបង្រៀនកងទ័ពថាកងនេះ កងនោះ ឈ្មោះនេះក្បត់ ធ្វើសកម្មភាព បង្អត់បាយ កងទ័ព កងទ័ពមិនត្រូវអត់បាយទេ ហេតុអីបានកងទ័ពអត់បាយ អីចឹងពួកហ្នឹងត្រៀមអង្ករ ត្រៀមថ្នាំពេទ្យ ដើម្បីវ៉ៃប៉ុលពត បើវ៉ៃប៉ុល ពត ត្រូវរបួសទៅភ្នំខត្ដុង្កនោះដឹងទៀត សែងទៅហ្នឹងរបួសសែងទៅហ្នឹង ។

ជ័យទត្ត: ពូដែនការដែលនាំឲ្យគេត្រៀមប៉ះបោរហ្នឹងដោយសារអីពូចាំទេ?

រឿង: ខ្ញុំចាំអត់បាន ។

ជ័យទត្ត: ឆ្នាំ៧៧?

រឿង: ហ្នឹងហើយឆ្នាំ៧៧ ។

ជ័យទត្ត: មូលហេតុអីដែលនាំឲ្យគេធ្វើអីចឹង?

រឿង: មូលហេតុនៅក្នុងកម្ពុជាប្រជាធិបតេយ្យមិនមែនកុំមុយនីស្តទាំងអស់ទេ ប្រទេសលោកសេរីខ្លះមាន វាមានខាងភ្នាក់ងារអាមេរិកខ្លះ ក្រោយមកគេចាប់ តាមការពិតមានហ៊ូ នឹម, ហ៊ូ យន់ ដែលគេថាខាងគាត់ភ្នាក់ងារអាមេរិក ក្រោយមកមានវ៉ន វេត គេទៅចាប់ក្រោយគេបំផុត ។ ដូច្នេះក្នុងជួររបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យមានវ៉ន វេត មួយទៀត ។

ជ័យទត្ត: គេចោទថាពួកគាត់ធ្វើ?

រឿង: ហ្នឹងមេគាត់នៅហ្នឹង គេចេះកសាងបណ្ដាញ ចេះតែធ្វើសកម្មភាពឲ្យកម្ពុជាប្រជាធិបតេយ្យដួលរលំ ព្រោះរឿងដួលរលំគឺរឿងសកម្មភាពនេះ ។

ជ័យទត្ត: ខ្ញុំងាកមកកន្លែងពូទៅប្រយុទ្ធជាមួយវៀតណាម ឆ្នាំណាពូនៅចាំទេ?

រឿង: ខ្ញុំចាំ ។

ជ័យទត្ត: ឆ្នាំណា?

រឿង: ឆ្នាំ៧៧ ។

ជ័យទត្ត: កាលហ្នឹងហេតុអីគេបញ្ជូនពូទៅប្រយុទ្ធជាមួយពួកវៀតណាម?

រឿង: កាលហ្នឹងដូចខ្ញុំនិយាយអីចឹង កាលហ្នឹងវៀតណាមនិងកម្ពុជា ដោះស្រាយទំនាស់គ្នាពិសេសនៅតាមព្រំដែន យើងត្រូវការដីត្រង់នេះដីយើង ដីគេ ខាងនោះថាដីគេ អីចឹងយើងដោះស្រាយគ្នាមិនចេញ រឿងកោះត្រល់ វ៉ៃតាំប៉ុល ពត បញ្ជូនកងទ័ពពួក១៦៤ទៅវ៉ៃ វៀតណាមចាប់ទាំងអស់ វ៉ៃយកកោះត្រល់ វ៉ៃយកម៉េចបាន ឆ្នាំហ្នឹងផែនការគេដឹងទាំងអស់ តាំងពីនាវាម៉ាយ៉េហ្គេសមក សកម្មភាពច្បាស់ណាស់ ព្រោះភ្នំពេញចេះតាមការពិតហ្នឹងខ្ញុំអត់និយាយទេ មិនកាន់ជើងខាងណាទេ ខ្ញុំនិយាយសកម្មភាពខ្មាំងសត្រូវ ក្រោយពី១៧

មេសា អឺចឹងប៉ុល ពត ជម្លៀសប្រជាជនតាមពួកគាត់មិនមែនគាត់ជម្លៀសយកទៅវ៉ៃចោលទេ គឺជម្លៀសរចនាសម្ព័ន្ធរបស់ទាហានរៀបចំវ៉ៃ គេរៀបចំរួចទៅហើយ ពេលកងទ័ពប៉ុលពតចូលភ្លីបភ្នំពេញគឺបាត់បង់អស់ហើយ មិនដឹងជាទៅណា ដាច់គ្នាអស់មែន ដល់ពេលហ្នឹងប៉ុល ពត ត្រូវបន្ទឹជម្លៀសប្រជាជនឲ្យអស់ ដើម្បីការវ៉ៃបកក្រោយបាត់អស់រលីង ឃើញអត់ ហ្នឹងផែនការ ។ រឿងគាត់យកប្រជាជន ឬគាត់យក១៧មេសា ឬឧត្តមសេនីយ៍ថ្នាក់ណា ឬខាងមូលដ្ឋាន ឬអាជ្ញាធររដ្ឋមន្ត្រី កុងសី ខ្ញុំមិនដឹងគេយកទៅណាទេ តែពេលហ្នឹងត្រូវជម្លៀសចេញទាំងអស់ ជម្លៀសចេញឲ្យលឿនជាទីបំផុត ដើម្បីកុំឲ្យខ្មាំងវ៉ៃបកក្រោយ ព្រោះពេលហ្នឹងមាននាវាម៉ាយ៉ាហ្គេសមួយមក ដែលកងទ័ពប៉ុលពត ចាប់បានប៉ុន្មានរយនាក់នោះក្នុងនាវាហ្នឹង មកហ្នឹងមកដើម្បីអីទេ? មកដើម្បីឲ្យឃើញថាត្រូវតែរើបំរាស់ ដល់ឆ្នាំ៧៦ មានយន្តហោះឡើងពីថៃមកទម្លាក់សៀមរាបទៀត សកម្មភាពដឹងទាំងអស់ គេឲ្យយើងដឹងតែម្តង អីចឹងភ្នាក់ងារ ខ្មាំងសត្រូវមាននៅក្នុងទៀតតែគេមិននិយាយថាអ្នកណាៗទេ ។

ជ័យទត្តៈ ខ្មាំងហ្នឹងគេសំដៅអ្នកណាវិញ?

រឿងៈ ខ្មាំងគេសំដៅអ្នកណាដែលចូលរួមសកម្មភាពហ្នឹងគេកំណត់ថាខ្មាំងហើយ ។

ជ័យទត្តៈ ចុះមានបរទេសទេ?

រឿងៈ ទេអត់មានបរទេសទេ ព្រោះអគ្គរាជទូតខ្ញុំឃើញផ្សេង ដូចអគ្គរាជទូតកាលហ្នឹងពេលដាច់ភ្នំពេញ គេមិនទាន់ចូលទៅស្រុក យើងការពារគេ ដូចទូតខាងខ្ទឹង, ទូតបារាំង ។

ជ័យទត្តៈ ដូចជនជាតិវៀតណាមយើងចាត់ទុកថាគាត់ខ្មាំង?

រឿងៈ ជនជាតិវៀតណាម ឯកអគ្គរាជទូតត្រូវដកចេញ ព្រោះដោះស្រាយគ្នាមិនចេញគេត្រូវដកចេញមុនហើយ តែកម្ពុជាមិនមែនអត់ទេ ជនជាតិវៀតណាមកគោក ។

ជ័យទត្តៈ ជនជាតិវៀតណាមសម័យកម្ពុជាប្រជាធិបតេយ្យ៣ឆ្នាំ?

រឿងៈ តាមការពិតជនជាតិវៀតណាមនៅក្នុងសម័យ៣ឆ្នាំ តាមការពិតមិនមែនគេអត់សម្លាប់ទេ គេសម្លាប់ គេថាយួន ហ្នឹងយើងនិយាយតាមនយោបាយប៉ុល ពត គាត់ថាយួន ហើយនឹងកម្ពុជាវាជាសត្រូវតកូន តចៅ ជិនាន់ដាំតែអុង ហ្នឹងខ្ញុំកើតមិនទាន់តែឯកសារគេប្រាប់មកអីចឹង ។

ជ័យទត្តៈ ឯកសារអីគេពូ?

រឿងៈ ឯកសារហ្នឹងចង់និយាយថាឯកសារប្រវត្តិសាស្ត្រ ។

ជ័យទត្តៈ ចុះពូដឹងថាកាលសម័យហ្នឹងវៀតណាមគេសម្លាប់ច្រើនទេ?

រឿង:	ច្រើន ស្លាប់ច្រើន ។

ជ័យទត្តៈ	គេសម្លាប់នៅណា មានដឹង?

រឿង:	មិនដឹងគេសម្លាប់នៅណាទេ ព្រោះខ្ញុំកងទ័ពមិនបានដឹងថាប្រជាជនយ៉ាងណាទេ សម័យ៣ឆ្នាំ ខ្ញុំបែកចេញពីផ្ទះទៅដល់ឡប់យួនចូលស្រុក ឡប់មកវិញ បានឃើញប្រព័ន្ធភ្លឺស្រែ ឃើញប្រឡាយ ព្រោះសម័យយើងមិនបានទេ គ្រាន់តែខ្ញុំបានចូលរួមកសាងម្តុំក្រាំងធ្នង់គ្រាន់តែបានធ្វើស្រែប៉ុន្មានខែ ក្រៅពីហ្នឹងជម្លោះតាមព្រំដែនគេហៅខ្ញុំទៅវៃជាប់ វៃតាំងពី៧៧-៧៨-៧៩ វៃជាប់ វៃភ្នំស្របុកមាន់ វៃម្តុំស្វាយរៀង ព្រៃវែង កំពង់ចាម ។

ជ័យទត្តៈ	វៃជាមួយវៀតណាម?

រឿង:	បាទ! វៃជាមួយវៀតណាម ចូលវៃទៅដល់ភ្នំដាយផ្ដែង ។

ជ័យទត្តៈ	ពូចូលដែល?

រឿង:	បាទ! ជាមួយ០៩កាលហ្នឹង ។

ជ័យទត្តៈ	ពូបានចូលរួមវៃដែរ?

រឿង:	បាទ! វៃជាមួយពួក០៩ ពួលតាហេង សំរិន, ជា ស៊ីម គាត់ក្ដាប់នៅបូព៌ ។

ជ័យទត្តៈ	គាត់ចូលវៃដែរ?

រឿង:	គាត់ទៅដែរ ។

ជ័យទត្តៈ	យើងវៃជាមួយគាត់ ឬមួយគាត់ចូលវៃ?

រឿង:	យើងសហការជាមួយគ្នា ព្រោះខាងលើគេបញ្ជាទៅ ។

ជ័យទត្តៈ	កាលហ្នឹងយើងវៃយ៉ាងម៉េចនៅក្នុងសមរភូមិ?

រឿង:	វៃកាលហ្នឹងចេះកងទ័ពវៀតណាមគេបញ្ជូនកងទ័ពមកច្រើនណាស់ ហើយគេមានកម្មវិធីគេមើលកុន ពីដើមមិនសូវមានឌីស្កូទេ ជំនាន់ហ្នឹងគេហៅថាមើលកុន មើលរឿងសង្គ្រាមដល់ហើយយើងវៃ យើងបាញ់កាំភ្លើង១៣០ទៅ យើងវៃដកមកវិញ ស្លាប់ច្រើនណាស់ ។

ជ័យទត្តៈ	ពូបានឃើញផ្ទាល់ភ្នែកតែម្ដង?

រឿង:	ខ្ញុំអត់បានឃើញផ្ទាល់ភ្នែកទេ ខ្ញុំនៅកន្លែងកាំភ្លើងធំ តែគេថាវាប់ដល់ហើយ សុទ្ធតែទ័ព វៃដាក់ទ័ព ។

ជ័យទត្តៈ	វៃហ្នឹងវៃទ័ពដែរ ឬប្រជាជន?

រឿង:	អត់ទេ កងទ័ពទាំងអស់ ទ័ពគេមកថាជួយរំដោះប្រជាជនឡូវចផុតពីរបបប្រល័យពូជសាសន៍ហ្នឹងនយោបាយខាងនោះ ។

ជ័យទត្តៈ	ទ័ពយើងខាងនេះទៅវៃ?

រឿង: វ៉ៃ ។

ជ័យទត្ត: ពូមានដឹងថាស្លាប់ប៉ុន្មាននាក់ខាងវៀតណាម?

រឿង: ខ្ញុំអត់ដឹងថាស្លាប់ប៉ុន្មានទេ ។

ជ័យទត្ត: តែស្លាប់ច្រើន?

រឿង: បាទ! ស្លាប់ច្រើនធម្មតាកងទ័ពមកនៅពេញដូចទីរួមស្រុកអន្លង់វែងអីចឹង យើងថាចេញទៅ វ៉ៃមិនមែនទៅភ្លាមឯណា គេមកកន្លែងទីរួមស្រុក ឬកន្លែងខេត្តអីមួយ ទៅមើលកុនមានអី ផែនការគេដឹងគេវ៉ៃ ។

ជ័យទត្ត: វ៉ៃខាងវៀតណាម?

រឿង: បាទ! ហ្នឹងការដោះស្រាយទំនាក់ទំនងព្រំដែនរវាងគ្នានឹងគ្នា វាមិនត្រូវគ្នាហើយ មានការវ៉ៃតប់ហើយម្យ៉ាងគេថារបបប៉ុលពតមានការកាប់សម្លាប់ប្រជាជន មានការបន្ទត់បាយ ការសម្លាប់មិនរើសមុខ ដល់អីចឹងកងទ័ពវៀតណាមគេមកជួយរំដោះ មកមានមកភ្លាមណា៎ មកនៅតាមព្រំដែនយប់ហ្នឹងយើងវ៉ៃ ។

ជ័យទត្ត: ស្លាប់ច្រើន?

រឿង: បាទ! ស្លាប់ច្រើន ។

ជ័យទត្ត: ពូមានដឹងថាសម័យមុនពេលវៀតណាមចូលមក ខាងថ្នាក់លើពូមានបង្រៀនពីរបៀបវៀតណាមនៅក្នុងប្រទេសរបស់យើងថាអាចមានខាងណាក្បត់ ឬគេបញ្ជូនទៅក្រៅអស់ហើយ?

រឿង: គេនិយាយដែរ គេថាយុទ្ធសាស្ត្ររបស់វៀតណាម គេថាផែនការរបស់វៀតណាមចង់គ្រប់គ្រង ឬចង់លេបយកកម្ពុជាដើមឆ្នាំ១៩៧៣ ។

ជ័យទត្ត: យើងមាន ។

រឿង: គេប្រាប់តាំងពី៧៣ បានយើងបង្កើតអង្គការខ្មែរដេញយួនចេញ យើងកំពុងតែវ៉ៃទាហាន លន់ នល់ អីចឹងមិនបាច់និយាយអីទេ សម្តេចហ៊ុន សែន គាត់ដឹងតា៎ ពេលហ្នឹងសម្តេចហ៊ុន សែន គាត់សុទ្ធតែកងទ័ពខ្មែរក្រហមទាំងអស់ជំនាន់ហ្នឹង មិនមានអ្នកណាមួយកងទ័ពក្រៅពីប៉ុល ពត១ក្តាប់ទាំងអស់ គ្រាន់តែក្រោយមកចលនាហ្នឹងគេមិនពេញចិត្តនឹងរបបហ្នឹងគេទៅនោះ ។

ជ័យទត្ត: អីចឹងបានន័យថាកងទ័ពគេបានដឹងថាខាងខ្មែរក្រហម ខាងអ្នកតស៊ូចង់ដេញយួនចេញពីស្រុកខ្មែរតាំងពីឆ្នាំ៧៣?

រឿង: មិនមែនចង់ដេញ តែដេញហើយ គេបង្កើតអង្គការខ្មែរនោះដេញវៀតណាមចេញពីស្រុក

ជ័យទត្ត: ពេលដេញហ្នឹងធ្វើម៉េចខ្លះ?

រឿនៈ ដេញៗ ប្រជាជនឲ្យទៅ ។

ជ័យទត្តៈ ប្រជាជនវៀតណាមទាំងអស់ចេញពីស្រុកខ្មែរ?

រឿនៈ ទៅផង សម្លាប់ផង ទៅមិនមែនទៅលេងៗណា ។

ជ័យទត្តៈ មានសម្លាប់ទៀត?

រឿនៈ មាន!

ជ័យទត្តៈ ពេលហ្នឹងគេដេញខេត្តណាខ្លះ? ពូមានចាំទេ?

រឿនៈ តាមខ្ញុំដឹងនៅខេត្តរតនគិរី កំពង់ចាម ឲ្យទៅ អ្នកណាទៅរួចៗ អ្នកណាមិនរួចងាប់ ។

ជ័យទត្តៈ ហ្នឹងខាងណាអ្នកដេញ? ខាងទាហានលន់ នល់ ឬមួយ?

រឿនៈ មិនមែនទាហានលន់ នល់ទេ ខាងកម្ពុជាប្រជាធិបតេយ្យនេះឯង កាលហ្នឹងចេះមិនមែនទាហានលន់ នល់ទេ ទាហានលន់ នល់ដេដៀលថាសម្ដេចសីហនុលក់ទឹកដីឲ្យយួន បទចំរៀងគេមាន លី ទឹក ច្រៀង ដៀលសម្ដេច ដៀលសីហនុថាលក់ខេត្តមកគិតឲ្យយួនជំនាន់ហ្នឹងខាងលន់ នល់ ហើយខាងនេះថាលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចឪដែលមានអាមេរិកគាំទ្រ វាបញ្ច្រាសបណ្ដោយគ្នាអីចឹង ។

ជ័យទត្តៈ ប៉ុន្តែយួននៅតែដេញចេញពីស្រុកខ្មែរតាំងពី៧៣?

រឿនៈ ប៉ុល ពត ទេអ្នកដេញ របបប៉ុល ពត អ្នកដេញ ។

ជ័យទត្តៈ មុនរំដោះហើយ?

រឿនៈ ៧១-៧២ខ្ញុំទៅវៃជាមួយយួនដែរ គេឲ្យដេញយួនចេញ តែក្នុងជួរទ័ពគេនិយាយថាវៀតណាមដកទៅស្រុក តាមការពិតគេដេញ របបប៉ុលពត ដេញយួនចេញពីស្រុក ព្រោះយួនមានផែនការលេបយកទឹកដីកម្ពុជាតាំងពីឆ្នាំ៧៣ ។

ជ័យទត្តៈ ថ្នាក់លើពូមានប្រាប់ពូទេពេលហ្នឹង?

រឿនៈ គេប្រាប់ គេហៅទៅរៀន យើងត្រូវឲ្យកងទ័ពវៀតណាមដកចេញពីស្រុក តែក្រៅគេនិយាយ ។

ជ័យទត្តៈ ជាក់ស្ដែងមានទេពូ?

រឿនៈ មាន ។

ជ័យទត្តៈ ពេលហ្នឹងយើងបណ្ដេញចេញចំណាយរយៈពេលប៉ុន្មាន?

រឿនៈ យើងដេញទៅហ្នឹង ដេញផង សម្លាប់ផង អីចឹងគេខឹងណាស់ ព្រោះគោលការណ៍គេថាមកជួយខ្មែរ តែជួយទៅវិញមិនមែនមកជួយខ្មែរចង់មកលេបទឹកដីកម្ពុជាតាំងពីមិនទាន់បានរំដោះពីលន់ នល់ ហ្នឹងផែនការខាងលើគេប្រាប់អីចឹង ។

ជ័យទត្តៈ ពូដឹងថាសម្លាប់ប្រហែលប៉ុន្មាន?

រឿងៈ យើងមិនដឹងថាសម្លាប់ប៉ុន្មានទេ ព្រោះតួនាទីមិនទាន់មាន ៧៣ហ្នឹងខ្ញុំកំពុងរើនៅម៉ុព្រៃកក្តាម ហ្នឹងការដេញមានកងគេផ្សេង ។

ជ័យទត្តៈ ថ្នាក់លើរបស់ពូអ្នកប្រាប់ពូ?

រឿងៈ បាទ!

ជ័យទត្តៈ ថ្នាក់លើហ្នឹងបើតាមពូដឹងគាត់ទទួលបញ្ជាពីលើមកទៀត ឬខ្លួនគាត់?

រឿងៈ ហ្នឹងជារឿងផ្ទៃក្នុង មិនមែនកងទ័ពទាំងអស់ដឹងទាំងអស់ទេ កងទ័ពខ្លះ រហូតដល់កងពល ឬអ្នកធំបើអត់តួនាទីក៏អត់ដឹង តែខ្ញុំនេះដឹង ខ្ញុំគេដាក់ខ្ញុំឈ្មោះ ជនចំរើន កិច្ចការផ្ទៃក្នុងគេដឹងគេប្រាប់ខ្ញុំ ជួនការគេហៅទៅរៀន មកវិញគេសួរឯងមកពីណា? ខាងលើហៅទៅរៀន និយាយតែប៉ុណ្ណឹង ហើយហាមដាច់ខាតមិនឲ្យប្រាប់ កិច្ចការផ្ទៃក្នុងគេអត់ឲ្យនិយាយណាទេ និយាយកុំមុយនីស្តគេហៅខាងសុនកក ឬបក្សពេញសិទ្ធ ។ ជនចំរើន មានច្រើនមាន ជនចំរើនត្រៀមទៅដល់បក្ស ។

ជ័យទត្តៈ តាមខ្ញុំចាំពូមានប្រសាសន៍ថាឆ្នាំ៧៣ ពូនៅក្រោមកែ ពក ត្រូវទេពូ?

រឿងៈ ៧២ខ្ញុំចូលកងទ័ព ដល់ពេល៧៣-៧៤គេបង្កើតចល័តភូមិភាគ ។

ជ័យទត្តៈ ពេលដែលដេញវៀតណាមនៅក្នុងចន្លោះឆ្នាំហ្នឹង?

រឿងៈ ឆ្នាំ៧៣គេដេញហ្នឹង ។

ជ័យទត្តៈ អីចឹងមេធំរបស់ពូនៅក្នុងភូមិភាគអ្នកណា?

រឿងៈ មេភូមិភាគ កាលហ្នឹងតាពក មេខ្ញុំ ខ្ញុំចល័តភូមិភាគ ។

ជ័យទត្តៈ ជំនាន់ដែលដេញវៀតណាមគឺជំនាន់៧៣?

រឿងៈ ដេញៗខ្ញុំមិនបានដេញទេ ខ្ញុំគ្រាន់តែជាដំណឹង គេមិនមែននិយាយដេញទេ គេថាកងទ័ពវៀតណាមដកចេញទៅស្រុក ដល់ក្រោយមកលឺថាវៀតណាមចង់ក្តោបយើងតាំងពីឆ្នាំ៧៣ តែយើងបង្កើតអង្គការខ្មែរដេញយួនទៅស្រុក ហ្នឹងគេខឹង ដេញផង សម្លាប់ផង បើអីចឹងគេខឹងទី១ ទី២ទៀតគឺវៀតណាមគាត់ឲ្យទៅជួយរើគាត់សិន កម្ពុជាប៉ុណ្ណឹងចាំរើក្រោយ ប៉ុល ពត អត់ព្រម បដិសេធន៍ដាច់ ទី៣ទៀតអាមេរិកកាំងត្រូវមានផែនការយកគ្រាប់បែកប៉ុន្មានតោនយកមកទម្លាក់លើប្រជាជន៧លាននាក់ ហ្នឹងផែនការ ប៉ុល ពត គេឲ្យគាត់ចរចាជាមួយអាមេរិក ប៉ុល ពត អត់ព្រមចរចារទៀត ដល់ប៉ុល ពត រើៗទៅឈ្នះ អីចឹងបានគេសួរថាប៉ុល ពត ជាអ្នកណានោះ? អីចឹងផែនការនេះសូម្បីតែសម្តេចហ៊ុន សែនក៏គាត់ដឹងដែរ គាត់ដឹងច្រើនមែនទែន ព្រោះគាត់កាលហ្នឹងគាត់ជាវៀមច្បង គាត់ចូល

មុន ដល់អីចឹងកិច្ចការផ្ទៃក្នុងគាត់ដឹងហើយ មិនមែនថាគាត់មិនដឹងទេ ហ្នឹងក្នុងចំណោមអ្នកតស៊ូពីមុន ខ្ញុំអត់និយាយពីប៉ុល ពត ទេ សម័យមុនរដ្ឋប្រហារ គាត់ក៏បានដឹងដែរ ។

ជ័យទត្តៈ ពូដែលឃើញគេសម្លាប់វៀតណាមផ្ទាល់ភ្នែកទេពេលហ្នឹង ឬពូបានដឹងពីព័ត៌មានហ្នឹង?

រឿងៈ កាលហ្នឹងដែលគេថាដេញយួនៗ៧៣ខ្ញុំមិនបានឃើញទេ ព្រោះអត់មានតួនាទីខ្ញុំទេ តួនាទីខ្ញុំកំពុងវៃជាមួយ លន់ នល់ វៃនៅម្តុំព្រែកក្តាម ។

ជ័យទត្តៈ អ្នកដែលប្រាប់ពូពីរឿងយើងមានគោលការណ៍ដេញវៀតណាម?

រឿងៈ ហ្នឹងហើយគោលការណ៍គេមាន ។

ជ័យទត្តៈ ថ្នាក់ណាដែលប្រាប់?

រឿងៈ ហ្នឹងនិយាយរួមកងទ័ពកម្មាភិបាលដឹងទូទៅ សូម្បីតែកូនទាហានក៏ដឹងដែរ ។

ជ័យទត្តៈ ពូកាលហ្នឹងមានដឹងថាតាពក គាត់មានតួនាទីធ្វើអី?

រឿងៈ តាពក គាត់មានតួនាទីក្តាប់ចល័តភូមិភាគឧត្តរ ។

ជ័យទត្តៈ ក្រៅពីហ្នឹងពូមានដឹងថាគាត់មានតួនាទីអីផ្សេងទៀតទេ?

រឿងៈ យើងអត់ដឹង យើងមិនអាចដឹងបាន ។

ជ័យទត្តៈ នៅក្នុងសម័យបន្ទាប់ពីមានគោលការណ៍ បន្ទាប់ពីយើងរំដោះបានយើងមានគោលនយោបាយអីជាមួយខាងវៀតណាម?

រឿងៈ យើងអត់មានគោលការណ៍អីជាមួយវៀតណាមទេ ក្រោយរំដោះមកយើងចង់និយាយថាកម្ពុជាមានប្រជាជន កម្ពុជាមានទឹកដី កម្ពុជាមានព្រៃ មានភូមិសាស្ត្រ មានភ្នំក្រាំថ្ម បើនិយាយពីទឹកដីកម្ពុជា ជាសិទ្ធិរបស់កម្ពុជា ។ ដល់អីចឹងយួនចង់មកគ្រប់គ្រងកម្ពុជា និយាយរួមចង់ដាក់នឹមត្រួតត្រាដូចអាណានិគមបារាំងអីចឹង តែគាត់អត់ព្រម រឿងប៉ុណ្ណឹងទេ ដែលនាំឲ្យប៉ុល ពត មានការស្លាប់ប្រជាជនរាប់លានគឺដោយសារអីចឹងទេ គាត់មិនត្រូវការឲ្យគេមកដាក់នឹមត្រួតត្រាលើខ្លួន ឥឡូវអូនឯងចាំសួរ អូនឯងចាំស្វែងរកទៅរឿងតែប៉ុណ្ណឹង ។

ជ័យទត្តៈ ខ្ញុំចង់សួរពូមួយទៀតទាក់ទងរឿងបងប្អូនជនជាតិចាម ថាពេលសម័យមុនឆ្នាំរំដោះយើងអត់មានបញ្ហាជាមួយបងប្អូនជនជាតិចាមទេ អីចឹងពូ?

រឿងៈ ហ្នឹងហើយ ។

ជ័យទត្តៈ ក្រោយមកដែលមានបញ្ហាជាមួយពួកគាត់ទេ?

រឿងៈ ក្រោយមកចាមលើសូរថា ក្រោយមកទេតែរឿងដាក់ស្តែងខ្ញុំអត់ដឹងមូលដ្ឋានក្រោយម៉េចទេកងទ័ពអត់ដឹងទេ កងទ័ពគេបញ្ជូនទៅវៃយួនព្រំដែន ស៊ីអត់ស៊ីឃ្លាន វេទនាស្លាប់រស់នៅហ្នឹង

ឯង មិនដឹងខាងក្រោយយ៉ាងណាទេ ក្រោយមកបានឮ ដល់មកបានឮថាជនជាតិខ្មែរឥស្លាម សម័យប៉ុល ពត គេសម្លាប់ច្រើនណាស់ ។

ជ័យទត្តៈ គេសម្លាប់ដោយសារមូលហេតុអីពូគេមានបានប្រាប់ពូ?

រឿងៈ គេសម្លាប់មូលហេតុថាចាមប្រុងបង្កលក្ខណៈធ្វើសកម្មភាព ខ្ញុំគ្រាន់តែឮអីចឹង តែមិនដឹងចលនាខាងណាទេ ដល់អីចឹងគេត្រូវការចាប់ខ្លួន ហើយគេបាននិយាយទៀតថាគេបំផុសបំផុលខ្មែរ-ឥស្លាមជំនាន់ហ្នឹងខ្ញុំក៏បានដឹងដែរ ថាខ្មែរឥស្លាមត្រូវតែងើបតស៊ូ ព្រោះទឹកដីខ្មែរ-ឥស្លាមជានគរចំប៉ានោះវាបាត់បង់នៅជំនាន់ណាៗខ្ញុំភ្លេចហើយ ។ បើអីចឹងឲ្យបងប្អូនចាមងើបឡើងធ្វើការតស៊ូឡើង នគរខ្មែរមិនមែនជានគររបស់ជនជាតិបងប្អូនទេ ជនជាតិបងប្អូនគេហៅនគរចំប៉ា ទីក្រុងព្រៃនគរ ឥឡូវគេដាក់ទីក្រុងអីក៏អត់ដឹងទេ ។

ជ័យទត្តៈ អ្នកដែលប្រាប់ពូអ្នកណាដែលពេលក្រោយមក?

រឿងៈ ក្រោយមកប្រជុំមេគេប្រាប់ ជួនណាមេខ្ញុំចាមដែរហ្នឹង ចំរុះគ្នា ។

ជ័យទត្តៈ មេពូចាមមកប្រាប់ពូថាជនជាតិ?

រឿងៈ ចាមនៅជាមួយគ្នា ឈ្មោះចាមឈ្មោះយ៉េះ, ឈ្មោះម៉ាត់ នៅជាមួយគ្នាស្គាល់ នៅជាមួយគ្នាបន្ទាប់គ្នាលេង នៅជាមួយគ្នារាល់ថ្ងៃ ថានេះទឹកដីឯងមិនមែននេះទេ ឯងកុំឆ្គួត ឯងកុំភ្លីនិយាយលេងសើចជាមួយគ្នា ធ្លាប់រែកជាមួយគ្នា ប្រាប់ថាឯងចាម ទឹកដីឯងនៅព្រៃនគរ ឯងទៅរំដោះនោះ វាថា២-៣នាក់ទៅម៉េច រួមគ្នាទៅ ហ្នឹងការនិយាយលេងទេ ។

ជ័យទត្តៈ និយាយលេងឆ្នាំណាពូ?

រឿងៈ និយាយលេងពេលដែលដាច់ប៉ុល ពត ហើយ ខ្វះធ្វើស្រែ ចេះតែនិយាយលេង ។

ជ័យទត្តៈ ក្រោយ៧៩?

រឿងៈ ៧៩ យួនចូលស្រុក ខ្វះមុនយួនចូលស្រុក យើងនៅជាមួយគ្នា កងមជ្ឈិមវានៅចំរុះគ្នា ។

ជ័យទត្តៈ តែពួកគាត់ដឹងថានៅខាងក្នុងនេះខាងបងប្អូនចាម ឥស្លាមគេសម្លាប់ច្រើន?

រឿងៈ គេសម្លាប់ច្រើនដែរ ខ្មែរយើងក៏ងាប់ គេក៏ងាប់ ប៉ុន្មានលាននាក់ មិនមែនតិចណា ។

ជ័យទត្តៈ តែពូដឹងមិនមែនដឹងនៅក្នុងអំឡុងពេលប៉ុល ពត?

រឿងៈ កងទ័ពនៅមុខមិនបានដឹងទេ ដឹងមកក្រោយហើយទេ បានរៀនសូត្រយួនចូលស្រុកហើយគេរៀនសូត្រ ។

ជ័យទត្តៈ នៅឆ្នាំណា?

រឿងៈ រៀនសូត្រនៅក្រោយឆ្នាំ៧៩ ។

ជ័យទត្តៈ អ្នកណាអ្នកបង្រៀន?

រឿង៖ រៀនមេៗហ្នឹង ខាងអគ្គសេនាធិការគេហៅទៅរៀន គេថាមិនមែនរបបហ្នឹងសម្លាប់ទេ ថាយួនអ្នកសម្លាប់ ។

ជ័យទត្ត៖ យួនអ្នកសម្លាប់ចាម?

រឿង៖ យួនអ្នកសម្លាប់ខ្មែរ រួមទាំងចាមផង ។ មូលហេតុអីបានយួនសម្លាប់ខ្មែរ មូលហេតុមកពី ប៉ុល ពត មិនទទួលយកអ៊ីដែលវៀតណាមគាត់ចង់បាន យើងដឹងតាំ ទទួលយកអ៊ីដែលមិនចង់បាន ចង់និយាយថាដាក់ត្រួតត្រាអាណានិគម ដូចជិនាន់បារាំង បារាំងមានតិចណា បារាំងមុននិងក្រោយ៩០ឆ្នាំ ហ្នឹងអីចឹង ។

ជ័យទត្ត៖ ពូអ្នកដែលបង្រៀនពូហ្នឹង បង្រៀននៅនេះ ឬបង្រៀននៅណា?

រឿង៖ រៀនពេលយួនចូលស្រុកហើយ រៀននៅព្រៃ តែរៀនហ្នឹងកន្លះខែ រៀនក្នុងព្រៃគេមានបាយមានទឹក មានកម្មវិធីគេរៀន រៀនដើម្បីឲ្យដឹងថាការសម្លាប់ខ្មែរមិនមែនខ្មែរសម្លាប់ខ្មែរទេ ខ្មែរសម្លាប់ខ្មែរមែនតែបំរើយុទ្ធសាស្ត្រឲ្យគេ គេរៀន និយាយការសម្លាប់ហ្នឹងគឺយួនមានផែនការសម្លាប់ខ្មែរដើម្បីឲ្យរបបហ្នឹងដួលរលំ ។

ជ័យទត្ត៖ ពូមានចាំទេអ្នកណាអ្នកបង្រៀនពូ?

រឿង៖ ខាងអគ្គសេនាធិការ ខាងលើគេមកបង្រៀន ។

ជ័យទត្ត៖ អ្នកណាអ្នកគ្រប់គ្រងនៅអគ្គសេនាធិការ?

រឿង៖ ហ្នឹងខាងប៉ុលពត អ្នកគ្រប់គ្រង ។

ជ័យទត្ត៖ ពូនៅដឹងដែរ?

រឿង៖ ដឹង ប៉ុលពត យួនចូលស្រុកគាត់ចេញពីភ្នំពេញហើយហ្នឹង ។

ជ័យទត្ត៖ គាត់អ្នកគ្រប់គ្រង តែគាត់មិនមែនអ្នកមកបង្រៀនទេ?

រឿង៖ អីចឹងបាននិយាយថាប៉ុល ពត គាត់មិនត្រូវការអីទាំងអស់ ប៉ុល ពត តាមខ្ញុំបានធ្វើសកម្មភាពនោះទៀត ទៅកសាងព្រលានយន្តហោះរួមជាមួយកងទ័ពដែលមានគ្នា៤ម៉ឺននាក់ទៅកសាងព្រលានយន្តហោះកំពង់ឆ្នាំង ពេលសម័យប៉ុលពតកាន់អំណាច ។ គាត់ធ្វើព្រលានយន្តហោះគឺ១០គីឡូ៤ជ្រុង១គឺថាព្រលានយន្តហោះនេះអាចចុះបានត្រឹមបេ៥២ អាចផ្ទុក១៦០តោនបាន ព្រោះយន្តហោះផែនការគាត់ឲ្យទៅទុកក្រោមភ្នំទាំងអស់ គាត់ឲ្យទៅកាយភ្នំទុកប្រកឲ្យយន្តហោះចូលទៅភ្នំ គ្រាប់ទុកហ្នឹងទាំងអស់ ហើយគាត់ថាផែនការរបស់គាត់ឆ្នាំផែនការធ្វើព្រលានយន្តហោះគាត់ធ្វើ៧ឆ្នាំហើយ គេអ្នកធ្វើថា១០ឆ្នាំហើយ ប៉ុលពតថាធ្វើតែ៧ឆ្នាំទេឲ្យសំរុកធ្វើ ធ្វើហ្នឹងផែនការរបស់ប៉ុលពតទាញខ្មែរក្រោម ទាញខ្មែរលើឲ្យមកជាខ្មែរមួយវិញ ហើយគាត់កសាងព្រលានយន្តហោះហ្នឹងដើម្បីប្រមូលកងទ័ពកម្ពុជាក្រោម

ច្រើនដែរ ថៃច្រើនដែរ ដល់អីចឹងផែនការរបស់បង្រួបបង្រួមខ្មែរឲ្យទៅជាខ្មែរតែមួយ ដើម្បីយកដីខ្មែរ គាត់អាងអីគាត់អាងព្រលានយន្តហោះដែលកំពុងតែធ្វើៗ បើរបបប៉ុលពត អត់មានការកាប់សម្លាប់ គាត់បានហ្នឹង កុំថាថៃប៉ុណ្ណក៏ទៅអត់រួចជាមួយគាត់ដែរ ផែនការ របស់គាត់ធ្វើសំបើមណាស់ ហើយមានគេអ្នកជួយគាត់ធ្វើ ។

ជ័យទត្តៈ ខាងណាជួយធ្វើ?

រឿងៈ យើងអត់ដឹងថាខាងណាទេ គេអ្នកជួយធ្វើ នៅពេលដែលគាត់កាន់អំណាចគាត់ចង់សំរេច ទិសដៅរបស់គាត់ ។

ជ័យទត្តៈ ខ្ញុំចង់រកមករឿងខាងសាសនា សម័យហ្នឹងឧទាហរណ៍ថាពូទៅប្រយុទ្ធនៅសមរភូមិមុខ ពេលហ្នឹងបានគោរពបុណ្យទាន ធ្វើចូលឆ្នាំ គេមានដែលធ្វើអីខ្លះ?

រឿងៈ រឿងខ្ញុំគឺអត់មានទេបុណ្យទាន កងទ័ពអត់មាន បើគ្រាន់តែចូលឆ្នាំ១៩៧២ធ្វើទាហានដាប់ ដល់រំដោះហើយបានមកធ្វើស្រែ១ឆ្នាំ សម័យប៉ុលពតអត់មានវត្តណា បើទិសដៅគេ រំលាយសាសនាចោល ។

ជ័យទត្តៈ អីចឹងពូ?

រឿងៈ បាទ!

ជ័យទត្តៈ ពូដឹងហ្នឹងពីអង្កាល់មក?

រឿងៈ ហ្នឹងក្រោយមកបានខ្ញុំដឹងទេ ព្រោះទ័ពយើងអត់ដឹងនៅក្រោយអីចឹងណា៎ គេនិយាយរឿង សហករណ៍ជឿនលឿន សហករណ៍កំរិតនេះកំរិតនោះប៉ុណ្ណឹង ខ្ញុំក៏បានដឹងថារបបនេះអត់ មានវត្តទេ អត់មានជំនឿសាសនាទេ ដឹងហ្នឹងហើយដែលធ្វើសកម្មភាពរហូតដល់ប៉ុលពត សម្លាប់ពលរដ្ឋនាក់ យល់អត់?

ជ័យទត្តៈ បាទ!

រឿងៈ បើអត់មានការប្រឆាំងម៉េចមានការសម្លាប់ ប្រឆាំងនឹងរបបហ្នឹងទៅ អត់មានវត្តម៉េច អត់ មានបុណ្យទានម៉េច ថាមានការ ការណា ថាមានការក្រោយ មុខអត់ទាន់មានអ្នកណាការ បើខ្ញុំអាយុ២៧-២៨លីវ កងទ័ព៣-៤រយនាក់មិនទាន់មានអ្នកណាការមួយ បើមិនដែល ឃើញនារីអីផង នៅតែព្រៃ ដាច់អស់មនោសញ្ចេតនាវវាងបុរស និងនារី មានអីគិតបើ កំពុងតែវាយួន ការពារទឹកដី គេបើយើងមិនតស៊ូ យើងឲ្យអ្នកណាទៅតស៊ូ អីចឹងបានថា មនុស្សមានកម្មពៀរ សម័យនេះយើងធ្វើ សម័យក្រោយគេក្រោយធ្វើ គេនិយាយមាន ហេតុផលរបស់គេ ។

ជ័យទត្តៈ នៅក្នុងទស្សនៈរបស់ខ្មែរក្រហម ខាងប៉ុលពត ខ្មែរយើងជាមួយវៀតណាមយ៉ាងម៉េចដែរ ពូ?

រឿងៈ ខ្មែរយើងជាមួយវៀតណាមគឺយុទ្ធសាស្ត្រគឺមិនត្រូវគ្នាតែម្តង តកូនតចៅជាមួយយួនគឺមិនត្រូវគ្នា ដាច់ខាតតែម្តង ។

ជ័យទត្តៈ បើយើងមើលទៅការដែលយើងអត់ត្រូវគ្នាមូលហេតុអីគេពូ?

រឿងៈ មូលហេតុអត់ត្រូវគ្នាដូចខ្ញុំថាម៉ិញ គាត់មិនត្រូវការអ្វី ព្រោះគាត់បាននិយាយហើយ ព្រោះហ្នឹងដែនការរបស់មេ គេហៅផ្ទៃក្នុងរបស់គេ មូលហេតុមកពីអាណានិគមមិនមែនស្រួលទេអូន គេមកមិនត្រឹមតែត្រួតត្រាលើយើងទេ មកត្រួតត្រាហើយគេទារពន្ធដារ យើងធ្វើអីប្រឆាំងអាណានិគមគេត្រូវចាប់យើងហើយ អាណានិគម៩០ឆ្នាំគិតទៅខ្មែរអស់ប៉ុន្មាននាក់ ខ្មែរដែលមានគំនិតប្រឆាំងអាណានិគម ដែលឯងមកធ្វើបាបខ្មែរ អូនឯងគិតទៅ៩០ឆ្នាំថាអស់មនុស្សប៉ុន្មាននាក់ ហ្នឹងអីចឹង ហ្នឹងខ្ញុំនិយាយខាងនេះ ខាងខ្មែរក្រហមដែលគាត់លើកឡើង មិនមែនធម្មតាទេ ។

ជ័យទត្តៈ ពូមួយទៀតនៅពេល អំឡុងពេលឆ្នាំ៧២-៧៣-៧៤ដែលពូនៅតស៊ូ នៅខាងកំពង់ចាមជិតមកភ្នំពេញ ពេលហ្នឹងពូមានដឹងថាព្រះពុទ្ធសាសនាត្រូវគេលុបបំបាត់ចោលទេ?

រឿងៈ ពេលហ្នឹងយើងអត់ទាន់ដឹងទេ គេមិនទាន់លុបសាសនាចោលទេ គេយកយើងប្រើសិនទេ សាសនា៧៥-៧៦បានដឹងថាអត់មានវត្តមែន ។

ជ័យទត្តៈ ពូដឹងផ្ទាល់?

រឿងៈ ដឹង បើយើងបានដឹង បានឃើញហើយ វាអត់មាន យើងនៅជាមួយប្រជាជនដែរ ។

ជ័យទត្តៈ អីចឹង?

រឿងៈ ដាច់ភ្នំពេញហើយខ្ញុំនៅជួយធ្វើស្រែប្រជាជននៅស្ពឺ ចំការលើ អត់មានវត្ត វិហារគេវ៉ៃចោលបានន័យថាអត់មានមែន សាសនាគេនិយាយដែលវាអត់មានហេតុផលអីទេ សាសនាវាគ្រាន់តែជំនឿមួយដែលប្រជាជនធ្វើមិនឲ្យមានគំនិតកេញប្រវ័ញ្ច ឬមានគំនិតជិះជាន់ មើលងាយ មើលថោកមនុស្សដទៃ វាគ្មានជាតិមុខ ជាតិក្រោយអីទេ តែស្លាប់ហើយ សូន្យហើយ អត់មានទេ គ្រាន់តែជាសាសនាដើម្បីគំរាមមនុស្ស កុំឲ្យមនុស្សប្រព្រឹត្តិអំពើបាបទេ គេនិយាយហេតុផលរបស់គេអីចឹង ។

ជ័យទត្តៈ ក្រៅពីព្រះពុទ្ធពូមានដឹងថាសាសនាផ្សេងទៀតគេទុកឲ្យដែរ ឬមួយគេធ្វើដូចព្រះពុទ្ធដែរ?

រឿងៈ រឿងសាសនាហ្នឹងតាមការពិតគេនិយាយតែរឿងសាសនា តែប៉ុណ្ណឹងរបបហ្នឹង អត់មានបាននិយាយសាសនាអីទៀត ។

ជ័យទត្តៈ ពូដឹងតែព្រះពុទ្ធទេ ក្រៅពីហ្នឹងដូចឥស្លាម ខាងម៉ូស្លីម ខាងគ្រិស្ត?

រឿងៈ ខាងចាមគេបាននិយាយដែរហ្នឹង ពីដើមម៉ិញនៅជាមួយគ្នា អញធ្លាប់ទៅថ្វាយបង្គំព្រះព្រះអី?

ជ័យទត្តៈ មហាម៉ាត់?

រឿងៈ មហាម៉ាត់ ចុះឥឡូវ? ឥឡូវឈប់ទាំងអស់គ្នា សាសនាព្រះពុទ្ធក៏អត់មាន សាសនាខ្មែរឥស្លាមក៏អត់មាន អត់មានវិហារគេវ៉ៃចោលខ្ទិចខ្ទីអស់ ខ្លះអីនៅប្រាំងចំរេះវិហារចាមគគោក ខ្លះគេវ៉ៃចោល ខ្លះគេមិនវ៉ៃចោល ចាស់ទ្រុឌទ្រោមបាក់បែកអស់ទៅ បន្ទាប់គ្នាល្អមើលដែរនៅជាមួយគ្នា ។

ជ័យទត្តៈ បន្ទាប់គ្នាសម័យណា?

រឿងៈ សម័យ៣ឆ្នាំ កំពុងតែធ្វើស្រែ ។

ជ័យទត្តៈ កំពុងតែធ្វើស្រែបន្ទាប់គ្នាដែរ?

រឿងៈ បាទ! បន្ទាប់គ្នាដែរ នោះស្រុកឯងនៅនោះ នគរចំប៉ា ទៅម្នាក់ឯងងាប់ ងាប់អីទៅមនុស្សច្រើន បន្ទាប់គ្នាលេង អីចឹងបានថាជូរចត់ណាស់ជីវិត តាំងពីអាយុ១៧មកគ្មានបានសប្បាយ គ្មានបានទៅមើលគេហៅថាល្បែងកុន ឬឃើញនារីណាដែលមានសម្ផស្ស ឬក៏ស្អាត ខ្មៅ ស មិនគិតទេ គិតតែរឿងថាការពារទឹកដី ការពារជាតិឲ្យរស់សិន ។

ជ័យទត្តៈ ពូពេលឆ្នាំ៧៥ពូចូលជួយរំដោះភ្នំពេញ?

រឿងៈ បាទ! ជួយវ៉ៃតាំងពី៧២-៧៥ ។

ជ័យទត្តៈ ចូលភ្នំពេញដែរ?

រឿងៈ ចូលភ្នំពេញដុក ។

ជ័យទត្តៈ នៅភ្នំពេញបានប៉ុន្មានឆ្នាំ?

រឿងៈ នៅភ្នំពេញបានប៉ុន្មានខែ ។

ជ័យទត្តៈ ពេលហ្នឹងនៅភ្នំពេញគេឲ្យធ្វើអីខ្លះ?

រឿងៈ នៅភ្នំពេញគេឲ្យជម្លៀសប្រជាជន តែខ្ញុំខាងការពារ អ្នកណាគេជម្លៀសៗទៅ ជម្លៀសហ្នឹងភាគច្រើនតែខាងមូលដ្ឋានទេ ទ័ពតែដាច់ភ្នំពេញគេដកចេញតាមអគ្គភាព គេដឹងផែនការដែរ គេឲ្យតែប្រជាជនខាងមូលដ្ឋានជម្លៀស មានទ័ពស្រុក មានទ័ពតំបន់ ទ័ពមជ្ឈិមអត់មានទេ ទ័ពមជ្ឈិមគេចាំមើលអាមេរិកដែលចាំវ៉ៃបកក្រោយ ផែនការរបស់គេ ។

ជ័យទត្តៈ ច្បាស់លាស់?

រឿងៈ ច្បាស់លាស់ ។

ជ័យទត្តៈ ខ្ញុំចង់សួរពូក្រោយពីសម័យពន្ធនាគារ បន្ទាប់ពីពន្ធនាគារហើយ ខាងទាហាន កងទ័ពខ្មែរក្រហម គាត់រត់មកខាងម្ដុំណា?

រឿងៈ ខ្មែរក្រហម?

ជ័យទត្តៈ ខាងពូ?

រឿងៈ ក្រោយពីវៃភ្នំពេញដាច់ហើយប្រគល់តួនាទីឲ្យពួកខាងកងទ័ពតំបន់ គេហៅទ័ពខេត្ត ទ័ពតំបន់ ឬកងភូមិភាគគេធ្វើការ យើងអត់បានចេញទៅណាទេ យើងទៅតាមផែនការខាងលើដែលឲ្យទៅនៅត្រង់ណាៗ រៀបចំ ។

ជ័យទត្តៈ អត់ទេ ចង់និយាយពីក្រោយ៧៩វិញ?

រឿងៈ ក្រោយ៧៩?

ជ័យទត្តៈ បាទ!

រឿងៈ ក្រោយ៧៩ខ្ញុំអត់ទាន់បានមកភ្នាមទេ ខ្ញុំនៅស្រុកយួន ។

ជ័យទត្តៈ ម៉េចបានទៅដល់ហ្នឹងវិញ?

រឿងៈ គេឲ្យទៅវៃហ្នឹង ។

ជ័យទត្តៈ នៅជាយដែន?

រឿងៈ នៅជាយដែន នៅភ្នំដេរប្ដី យួនចូលស្រុកខ្ញុំមកមិនទាន់ ខ្ញុំនៅនោះឡើយ ដល់មកប្រជាជនដេញកាប់ គេថាពួកអាពតទៅហើយ ពួកខ្ញុំរហ័ស ប្រជាជនម៉េចដេរពួកយើងវិញ ខ្ញុំអត់ដឹង ហើយយើងអត់ដឹងរឿងផង ដល់អីចឹងខ្ញុំចូលមកដល់ភូមិក្រូចឆ្មា គេនិយាយជម្លៀសប្រជាជនទៅលិច បុកស្រុកមេមត់ ប្រជាជនប្រហែលរាប់ពាន់នាក់មានរទេះ មានគោទៅ គេជម្លៀស ពួកខ្ញុំយកគាត់មកវិញ មកដល់ស្រុកក្រូចឆ្មារ ឃើញមានរោងចក្រគេធ្វើក្រដាសនៅហ្នឹង ទៅសួរគាត់ អត់ប្រាប់គាត់ខ្លាចយើង ដល់សួរប្រធានភូមិអតីតប្រធានភូមិរបបប៉ុលពតហ្នឹង សួរគាត់ទៅ អ៊ំនិយាយប្រាប់តិចមករបបខាងក្រោយវាយ៉ាងម៉េច? ហើយបានជាឃើញកងទ័ពខ្ញុំមកពីស្រុកយួនឆ្លងមកវិញ ស្រាប់តែប្រជាជនដេញកាប់ដេញកាប់មែនហើយយើងសុទ្ធតែកាំភ្លើង គាត់មកកាប់ កងទ័ពអាពតមកវិញបាក់ទ័ព មានគេអ្នកនាំ ៣-៤នាក់ គេបាញ់មកលើយើង៣-៤គ្រាប់ ហើយយើងទៅបាញ់អីសុទ្ធតែប្រជាជន បើបាញ់ទុចៗ២-៣គ្រាប់គេរត់អស់ហើយ យើងមកជួបជុំ ហៅប្រជាជនមកសួរ ថាពេលនេះបងប្អូននិយាយប្រាប់ខ្ញុំឲ្យច្បាស់តើរបបកម្ពុជាប្រជាធិបតេយ្យខាងក្រោយធ្វើសកម្មភាពអីខ្លះបានប្រជាជនឃើញខ្ញុំមក ហៅទ័ពអាពតៗ គាត់និយាយប្រាប់ កុំខ្លាចឲ្យសោះ ហើយបើមានសកម្មភាពដូចប្រជាជនស្អប់មែន ខ្ញុំនឹងទៅវៃអាពត បានគាត់ជូនមក

កុំអីមកមិនបានទេ គាត់ជូនមកឆ្នងទន្លេ ឡើងកាណូតនៅស្រុកក្រូចឆ្មារមកឡើងស៊ីងត្រង់ បានកប៉ាល់ហ្នឹងឡប់មកវិញ តាមការពិតកប៉ាល់ហ្នឹងគេអត់ឲ្យមកទេ ខ្ញុំថាខ្ញុំទៅវិញទៅដឹកកងទ័ពមកទៀត បានកប៉ាល់ហ្នឹងឲ្យមក តាមការពិតឆ្លងស៊ីងត្រង់កងទ័ពឡើងទៅកប៉ាល់ហ្នឹងវាអត់ចង់ឲ្យមកទេ ខ្ញុំថាទៅយកកំលាំងមកទៀត បានគេឲ្យមក កំលាំងខ្ញុំអស់ហើយ កំលាំង១ពាន់នាក់ជាង ជិះកប៉ាល់២គ្រឿងអត់អស់ផង ។

ជ័យទត្តៈ ពួសម័យហ្នឹងមានឃើញខាងទាហានខ្មែរក្រហមទៅចាប់ពួកវៀតណាមទៀត ពេលបែក ហើយពេលក្រោយ៧៩?

រឿងៈ មានតា៎ ខ្ញុំឃើញចាប់បាន ។

ជ័យទត្តៈ ចាប់បានដែរ?

រឿងៈ ចាប់បានច្រើនណាស់ កាលហ្នឹងចេះក្រោយពីយួនចូលស្រុកហើយ ខ្មែរក្រហមគេធ្វើរណសិរ្សជំនាន់ហ្នឹង រណសិរ្សហ្នឹងគឺថាទាំងប្រជាជនយើងប្រមូលបងប្អូនគ្រប់ជនជាតិនៅកម្ពុជា មិនថាជនជាតិណា មិនថាថ្នាក់ណា មិនថាអ្នកមាន អ្នកក្រ មិនថាលោកសង្ឃ ឲ្យតែដេវ អាខ្មាំងយួនមួយម៉ាត់ គេប្រមូលទាំងអស់ ។ នៅពេលប៉ុលពត គាត់ធ្វើរណសិរ្សគាត់ប្រកាសតាមវិទ្យុ ឲ្យវៀតណាមស្រីម្នាក់និយាយប៉ុស្តិ៍ហ្នឹងមានម៉ោងគេនិយាយ មករាប់ពាន់នាក់ជូនមកសុទ្ធតែកងទ័ពវៀតណាមទៅនៅ១០០៣ បើកអន្តរស៊ី តែវៀតណាមហ្នឹងបានទៅប្រទេសទីពាទាំងអស់ អំពាវនាវ សុទ្ធតែសិស្សសាលា គេឲ្យមកជួយច្រូតស្រូវនៅកម្ពុជា ដល់មកគេឲ្យស្ពាយកាំភ្លើងមកវ៉ៃខ្មែរក្រហម គ្មានអត់ធ្លាប់ធ្វើ ក៏ចូលមកហូង១ខ្លះ ៣០នាក់, ៤០នាក់, ៥០នាក់តាមការអំពាវនាវរបស់យើង យើងឲ្យគេអំពាវនាវតាមវិទ្យុ នោះគេនិយាយភាសាវៀតណាម ជញ្ជូនថាមួយខែ១ជញ្ជូន២-៣ជើង អូនឯងស្រុកជីក្រែងមកភ្នំដងរែក ។

ជ័យទត្តៈ គេចាប់បាន?

រឿងៈ គេមកចូលជាមួយយើង យើងនាំគេ កាលហ្នឹងធ្វើរណសិរ្ស ។

ជ័យទត្តៈ វៀតណាមមកចូលជាមួយយើងវិញ?

រឿងៈ កាលហ្នឹងក្រោយ៧៩គេឲ្យវៀតណាមមកវ៉ៃខ្មែរក្រហម តែការពិតឲ្យមកច្រូតស្រូវ តែមកគេឲ្យស្ពាយកាំភ្លើងមកវ៉ៃខ្មែរក្រហម យល់អត់?

ជ័យទត្តៈ យល់ ។

រឿនៈ	សភាពការណ៍គេឃើញ គេដឹង គេធ្វើរណសិរ្ស គេប្រមូលកងទ័ព គ្នាមិនដែលច្បាំង គេកុហកមកប្រូតស្រូវ ស្តាយកាំភ្លើងឲ្យមកវ៉ៃខ្មែរក្រហម អីចឹងគេអំពាវនាវ គេមានកម្មវិធីរបស់គេ គេសុទ្ធតែដឹង កងទ័ពវៀតណាមមិនមែនមកវ៉ៃទេ ចាញ់នយោបាយគេ ។

ជ័យទត្តៈ	ពេលហ្នឹងចាប់ទេ ឬមួយក៏យើងអត់ចាប់ទេ?

រឿនៈ	ឧទាហរណ៍ថាមកតាមភូមិ មានកងទ័ពវៀតណាម១០ អីចឹងយើងហៅគេមក ។

ជ័យទត្តៈ	តែអត់ចាប់ទេ?

រឿនៈ	អត់មានកាំភ្លើងទេ យកកាំភ្លើងមកម៉េចរួច សុទ្ធតែរត់ ពួកអ្នករត់ រត់ចោលអគ្គភាព ដូចកងទ័ពវៀតណាមនៅបោះប្រចាំស្រុកអន្លង់វែង គេត្រូវការចេញ គេទុកកាំភ្លើងចោលរត់ រត់តែខ្លួនទទេ រត់ក៏យើងជូនទៅ ប្រជាជនជូនទៅ យើងជូនទៅទៀត ។

ជ័យទត្តៈ	តែអត់ធ្វើអីគេទេ?

រឿនៈ	អត់ធ្វើអីទេ គេធ្វើរណសិរ្សប្រកាសវិទ្យុ ។

ជ័យទត្តៈ	ចុះបើក្រៅពីអ្នកធ្វើរណសិរ្ស?

រឿនៈ	អត់ទេ ពេលហ្នឹងគេអត់ធ្វើអីទេ អ្នកណាវ៉ៃៗ អ្នកណាស្លាប់ៗ អ្នកណារបួសៗ អ្នកចូលៗមកគេធ្វើរណសិរ្សគេប្រកាសតាមវិទ្យុ ។

ប្រុញៈ	ចុះពូនិយាយម៉ិញឲ្យតែជេរអាខ្មាំងយួន?

រឿនៈ	ពេលហ្នឹងអ្នកណាជេរខ្មាំងយួនក៏គេយកដែរ គាំទ្រខាងផ្លូវចិត្ត គេយកតាមភូមិ អាខ្មាំងយួនហ្នឹងក៏គេគាំទ្រដែរ មនុស្សហ្នឹងមានគំនិតល្អ ។

ប្រុញៈ	អីចឹងប្រមូលយកមក?

រឿនៈ	យើងមិនប្រមូលទេ គ្រាន់តែមានសណ្តានចិត្ត ឬមិនឱបដៃនៅស្ងៀមក៏ប្រឆាំងនឹងយួនដែរប្រាប់ដំណឹងថាយួនមកហើយហ្នឹងក៏អ្នកស្នេហាជាតិដែរ ឬឲ្យបាយបញ្ចប់ហូប ហ្នឹងគេនិយាយអីចឹង ឲ្យតែជេរខ្មាំងយួនក៏គេយកដែរ មិនបានធ្វើអីក៏ដោយ ឲ្យតែអាខ្មាំងយួនហ្នឹងរណសិរ្សប្រមូលហើយ ប្រមូលខាងអី ប្រមូលខាងគាំទ្រខាងផ្លូវចិត្ត ឬគាំទ្រឲ្យបាយស៊ីពាក្យហ្នឹងអីចឹង ។

ជ័យទត្តៈ	ប្រហែលជាដូចពួកខ្ញុំអស់អីសួរពូទៀតហើយ វាលំអិតពេក ។

រឿនៈ	វាអត់ល្អិតទេអូន ព្រោះយើងមិននិយាយតាមឯកសារ យើងនិយាយតាមដំណាក់កាល ។

ជ័យទត្តៈ	សំនួរឆ្លើយ ។

ប្រុញៈ	អត់ទោសពូសុំសួរតិច ក្នុងឆ្នាំ៧២-៧៣លឺថាពូមានហៅអ្នកធ្លាប់ទៅរៀនសូត្រនៅវៀត-ណាមយកមកសម្លាប់ ពូមានដឹងរឿងហ្នឹង?

រឿន:	ហ្នឹងខ្ញុំដឹងដែរ ។

ប្រុញ:	ម៉េចទៅហ្នឹង?

រឿន:	អាហ្នឹងតាមការពិតទៅ គេហៅថាយើងទៅរៀនបច្ចេកទេស ទៅវៀតណាមដើម្បីយកបច្ចេកទេសមកហ្វឹកហាត់កងទ័ពខ្លួនឯង ដើម្បីខ្លួនឯងវៃខ្មាំងសត្រូវរំដោះប្រទេស ។ កាលអ្នកទៅមិនមែនគេវៃចោលទាំងអស់ទេ ឬមិនយកធ្វើម៉េចទេ ហ្នឹងយុទ្ធសាស្ត្ររបស់គេ យើងទៅរៀនហ្នឹងចង់និយាយថាយើងទៅរៀនពីអី ព្រោះក្នុងហ្នឹងមានគេទៅដែរ មិនមែនតែយើងណា៎ មិនមែនថាគេមិនដឹងទេ គេដឹង ព្រោះសហប្រតិបត្តិការគ្នារវាងកងទ័ពវៀតណាមខាងជើង ដែលគាត់ធ្វើសង្គ្រាមរំដោះវៀតណាមខាងត្បូងគឺមានសហការណ៍ពីយើងដែរ បើយើងមិនសហប្រតិបត្តិការទេវៀតណាមក៏មិនបានរំដោះប្រទេសដល់សព្វថ្ងៃដែរ ព្រោះការស្នាក់អាស្រ័យគឺយើង ការផ្តល់ទីជំរកគឺយើង យល់អត់?

ជ័យទត្ត:	បាទ!

រឿន:	អីចឹងអ្នកឯងរំដោះប្រទេសវៀតណាមខាងត្បូងទាំងមូលរហូតដល់សព្វថ្ងៃ ក៏ដោយសារប្រទេសកម្ពុជាដែរ ជាគុណបំណាច់របស់កម្ពុជាដែរ ហើយពេលហ្នឹងមិនមែនលន់ នល់ អ្នកគ្រប់គ្រងណា ជនបទគឺប៉ុលពត អ្នកគ្រប់គ្រង គឺកំលាំងតស៊ូរបស់សម្តេចនរោត្តមសីហនុដែលគាត់តស៊ូ អីចឹងមានតែពួកណា មានតែពួកហ្នឹង កំលាំងហ្នឹង យើងនិយាយឲ្យឃើញក្រោយមកទៀតគេថាកុំតែបានវៀតណាមមកជួយរំដោះ ប្រជាជនឲ្យផុតពីរបបប្រល័យពូជសាសន៍ កុំអីអាពតវាសម្លាប់ហើយ ឃើញទេនយោបាយវាអីចឹង ។

ជ័យទត្ត:	ខ្ញុំប្រហែលជាមានសំនួរចុងក្រោយមួយទៀត សំនួរហ្នឹងចង់សួរពូថា ពូធ្លាប់លឺគេថាអ្នកដែលមានគ្រួសារជាជនជាតិវៀតណាម ឧទាហរណ៍ថាប្តីជាវៀតណាម ប្រពន្ធជាខ្មែរគេសម្លាប់តែប្តីទេ បើប្រពន្ធជាជនវៀតណាម?

រឿន:	តាមការពិតមែន ។

ជ័យទត្ត:	ពូធ្លាប់លឺទេ?

រឿន:	មិនមែនធ្លាប់លឺទេ ធ្លាប់ឃើញ ឪពុកធំខ្ញុំគាត់យកប្រពន្ធយួន អីចឹងវាឲ្យយួនទៅតែឪពុកមានៅ កាលហ្នឹងគាត់អត់ទាន់ស្លាប់សម័យហ្នឹង ។ យួនទៅស្រុកទៅមិនដឹងទៅណា តែទៅស្រុក ៗតាមគេទៅ ។

ជ័យទត្ត:	ឆ្នាំណា?

រឿន:	ឆ្នាំក្រោយរំដោះហើយ?

ជ័យទត្ត:	ក្រោយរំដោះឆ្នាំ៧៥ ឬ៧៩?

រឿង:	មិនទាន់រំដោះទេ ឆ្នាំណាទេខ្ញុំអត់សូវចាំច្បាស់ដែរ សភាពការណ៍ខ្ញុំមកក្រោយហើយបានដឹង ៧៣-៧៤ ឬ៧៥ ។

ជ័យទត្តៈ	ឪពុកមាពូឈ្មោះអី? ហើយគាត់ធ្វើអី?

រឿង:	ឈ្មោះ អ៊ុម ឆែម តែគាត់ស្លាប់បាត់ហើយ ។

ជ័យទត្តៈ	សម័យនោះគាត់ធ្វើអី?

រឿង:	សម័យនោះគាត់មិនធ្វើអីទេ គាត់នៅប្រជាពលរដ្ឋធម្មតា គាត់ទៅនៅភ្នំពេញគាត់បានប្រពន្ធយួន ។

ជ័យទត្តៈ	គេឲ្យប្រពន្ធយួនទៅវិញ?

រឿង:	បានប្រពន្ធយួន ដល់ពេលដាច់ភ្នំពេញមក គាត់បបួលប្រពន្ធកូនគាត់មកនៅគេហៅខាងជើងស្ពានស្ទឹងសែននេះ គាត់ទើបតែស្លាប់ប្រហែលប៉ុន្មានឆ្នាំ ។

ជ័យទត្តៈ	តែខ្មែរក្រហមអ្នកដេញចេញ?

រឿង:	វាថាយួនប្រពន្ធគាត់វាយកទៅស្រុកបាត់ហើយ មិនដឹងជាយកទៅស្រុកណា ស្រុកដើមឬស្រុកគេថ្មីមិនដឹង គេថាអីចឹង ។

ជ័យទត្តៈ	ពូធ្លាប់ជួបហើយ មានដែលលឺព័ត៌មានអីចឹងៗពេលក្រោយបែកមកទៀតទេ?

រឿង:	ក្រោយមកច្រើនលឺដែរ លឺថាយួនភាគច្រើនគេសម្លាប់ចោល អ្នកដែលជិតព្រំដែន កន្លែងណាដែលគេថាជិតត្រចៀក ជិតច្រមុះគេឲ្យទៅ បើស្ងាត់ៗគេវ៉ៃចោល គ្រាន់តែរូបភាពយើងមិនមាន មានអីអូនសម័យហ្នឹង សូម្បីតែគេអូមានតែអត្តភាពគេអូសម័យខ្មែរក្រហមមានស្អី មិនមែនដូចឥឡូវខ្វះអី ។

ជ័យទត្តៈ	ខ្ញុំដូចជាអស់សំនួរ អរគុណពូច្រើនដែលបានចំណាយពេលជាងមួយម៉ោងផ្តល់បទសម្ភាសន៍លំអិតល្អពូ អីចឹងខ្ញុំអរគុណ ។

រឿង:	អរគុណច្រើន ។

ចប់